អត្តចរិតរបស់អ្នក ដើរតាមព្រះយេស៊ូវ

គម្រោងនៃការបង្កើតសិស្ស

គបស៤

NAVPRESS
Discipleship Inside Out®

សាឡូមកម្ពុជា
www.smcambodia.org

NAVPRESS
Discipleship Inside Out®

NavPress គឺជាព័ន្ធកិច្ចនៃការបោះពុម្ពរបស់ The Navigators ដែលជាអង្គការគ្រីស្ទបរិស័ទអន្តរជាតិ ហើយជាអង្គការដែលឈានមុខគេខាងការអភិវឌ្ឍផ្នែកព្រលឹងវិញ្ញាណរបស់មនុស្ស។ NavPress បានប្ដេជ្ញាចិត្តក្នុងការជួយមនុស្សឲ្យមានការលូតលាស់ផ្នែកព្រលឹងវិញ្ញាណ ហើយឲ្យមានអំណរទៅនឹងជីវិតដ៏មានន័យ ព្រមទាំងឲ្យមានសង្ឃឹមតាមរយៈធនធាននៃការសិក្សាផ្ទាល់ខ្លួន ឬការសិក្សាជាក្រុមដែលក្រុម The Navigators បាននិពន្ធ ពីព្រោះមូលដ្ឋានគ្រឹះនៃធនធានទាំងនេះបានដកស្រង់ចេញពីព្រះគម្ពីរ ហើយក៏ផ្ដល់ភាពងាយស្រួលក្នុងការអនុវត្តដល់វប្បធម៌ផ្សេងៗទៀតផងដែរ។

បកប្រែដោយ បេសកកម្មសាឡូមកម្ពុជា និង សកម្មភាពកម្ពុជា

Translated by: Shalom Mission Cambodia - http://www.smcambodia.org

and ACTION Cambodia - http://www.actioncambodia.org

ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ សាំង ឈិនហូរ, ហុង សុភក្តិ, ជួប ប៊ុនហាក់,
ផេង វណ្ណៈ, ឈាង បូរ៉ា និង សកម្មភាពកម្ពុជា

Edited by: Chhinho Saing, Sopheak Hong, Bunhak Chuop,
Vannak Pheng, Bora Chheang and Action Cambodia

ព្រមជាមួយនឹងការប្រើប្រាស់កម្មវិធីត្រួតពិនិត្យអក្ខរាវិរុទ្ធ
និងវេយ្យាករណ៍ យូនីកូដខ្មែរ របស់ ស.ស.ឈ.ន.ក.
Using the SBBIC Unicode Khmer Spelling Checker
and Grammar Checker - http://www.sbbic.org

© 1973, 1980, 2006, 2013 by The Navigators

All rights reserved. No part of this publication may be reproduced in any form without written permission from NavPress, P.O. Box 35001, Colorado Springs, CO 80935.
www.navpress.com

NAVPRESS and the NAVPRESS logo are registered trademarks of NavPress. Absence of ® in connection with marks of NavPress or other parties does not indicate an absence of registration of those marks.

ISBN 978-0-9890481-01

Cover design by Arvid Wallen
Cover illustration by Michael Halbert
Interior design by The DesignWorks Group
រចនាអត្ថបទភាសាខ្មែរ : សេង ធា និង ម៉ែន ជំនោ
Khmer layout: Tia Seng and Chomneau Men
Creative Team: Dan Rich, Kathy Mosier, Arvid Wallen, Pamela Poll, Pat Reinheimer, Kathy Guist
Original DFD Author: Chuck Broughton

Revision Team: Dennis Stokes, Judy Gomoll, Christine Weddle, Ralph Ennis

អត្ថបទគម្ពីរ © រក្សាសិទ្ធិដោយសមាគមព្រះគម្ពីរសកល-ដកស្រង់ដោយមានការអនុញ្ញាត

Printed at i-Print CO., LTD., in Phnom Penh, Cambodia, 2013

គបស៤ | មាតិកា

ការសាងសង់ដើម្បីគុណភាព ៥

ជំពូកទី១
ការត្រាស់ហៅចំពោះការរស់នៅប្រកបដោយផលផ្លែ ៩

ជំពូកទី២
សកម្មភាពនៃសេចក្តីស្រឡាញ់ដែលឥតពុតមាយា ៣១

ជំពូកទី៣
ភាពបរិសុទ្ធនៃជីវិត ៥៥

ជំពូកទី៤
ភាពស្អាតស្អំក្នុងការរស់នៅ ៨១

ជំពូកទី៥
ការអភិវឌ្ឍផ្នែកអត្តចរិតក្នុងការរងទុក្ខ ១០១



ការសាងសង់ដើម្បីគុណភាព

បន្ទាប់ពីបានបញ្ចប់សៀវភៅ៣ក្បាលដំបូងដែលជាសៀវភៅ “គម្រោងនៃការបង្កើតសិស្ស” រួចមកហើយនោះ លោកអ្នកបានដឹងអំពីគុណប្រយោជន៍នៃការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនហើយ ថាតើវាមានអត្ថន័យដូចម្ដេចក្នុងការស្រាវជ្រាវស្វែងយល់ពីព្រះបន្ទូល និងការស្វែងរកព្រះយេស៊ូវដែលជាផ្លូវ ជាសេចក្ដីពិត ហើយជាជីវិតនោះ។ លោកអ្នកក៏ប្រហែលជាបានកត់សម្គាល់ឃើញថា នៅពេលដែលលោកអ្នកឆ្លើយតបទៅនឹងព្រះជាម្ចាស់ ហើយដកពិសោធន៍នូវព្រះបន្ទូលរបស់ទ្រង់ នោះលោកអ្នកនឹងបានទទួលនូវឥទ្ធិពលលើផ្នែកអត្តចរិត និងសកម្មភាពរបស់លោកអ្នកពីមួយថ្ងៃទៅមួយថ្ងៃជាមិនខាន។

ប៉ុន្តែ ទោះបីលោកអ្នកដឹងពីសារៈសំខាន់នៃការរស់នៅដែលស្របតាមព្រះបន្ទូលព្រះក៏ដោយ ក៏ប្រហែលជាវិញ្ញាណលោកអ្នក នៅតែប្រឆាំងទាស់នឹងអ្វីដែលលោកអ្នកបានសិក្សានោះដែរ។ សត្រូវរបស់គ្រីស្ទបរិស័ទគ្រប់រូបគឺ “សាតាំង” វាស្គាល់ពីអំណាចនៃព្រះបន្ទូលព្រះដ៏រស់ ហើយវាព្យាយាមរារាំងលោកអ្នកគ្រប់មធ្យោបាយ ដើម្បីឲ្យលោកអ្នកបានឃ្លាតចេញឆ្ងាយពីព្រះបន្ទូល។

វានឹងនាំលោកអ្នកឲ្យចេះដោះសារដូចជា “លោកអ្នកមានការរវល់ជាខ្លាំង” ឬ “លោកអ្នកមិនអាចផ្ដោតការយកចិត្តទុកដាក់ឥឡូវបានទេ គឺធ្វើការផ្សេងសិន ចាំមកសិក្សាព្រះគម្ពីរជាក្រោយ”។ វានឹងធ្វើឲ្យមានការរំខាន ការល្បួង និងការទិតៀនពីសំណាក់អ្នកខាងក្រៅ ដើម្បីឲ្យលោកអ្នកមានការអាក់ខានក្នុងការសិក្សាព្រះបន្ទូលព្រះ។

ការទទួលស្គាល់ថា សាតាំងគឺជាប្រភពដ៏ខ្លាំងមួយដែលបង្អាក់យើងពីការសិក្សាព្រះបន្ទូល គឺបញ្ជាក់បន្ថែមទៀតពីសារៈសំខាន់នៃការសិក្សាព្រះគម្ពីរ ហើយអាចជួយលោកអ្នកក្នុងការបង្កើនការសម្រេចចិត្តដើម្បីទទួលបានជ័យជម្នះ។ តើលោកអ្នកអាចយកឈ្នះវាបានដោយរបៀបណា? ខាងក្រោមនេះគឺជាការណែនាំខ្លះៗដែលលោកអ្នកអាចយកទៅអនុវត្តបាន៖

១. **ចូរទទួលស្គាល់**ដោយជំនឿថា ព្រះគ្រីស្ទបានយកឈ្នះលើសាតាំង និងគ្រប់ទាំងគម្រោងអាក្រក់របស់វា។ “តែអរព្រះគុណដល់ព្រះអង្គ ពីព្រោះទ្រង់ប្រទានឲ្យយើងរាល់គ្នាមានជ័យជំនះ ដោយសារព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង” (១កូរិនថូស ១៥:៥៧)។

២. **ចូរទូលសូម**កម្លាំង និងប្រាជ្ញាពីព្រះជាម្ចាស់តាមរយៈការអធិស្ឋាន។

៣. **ចូរប្រើ**ការដាក់វិន័យផ្ទាល់ខ្លួន ដើម្បីដកបទពិសោធន៍ពីព្រះគុណនៃព្រះជាម្ចាស់។ លោកអ្នកត្រូវខំប្រឹងចំណាយពេលស្ងៀមស្ងាត់ជាមួយព្រះជាម្ចាស់ ដូចគ្នាទៅនឹងការដែលលោកអ្នកត្រូវធ្វើគម្រោង ហើយរក្សាម៉ោងសិក្សារបស់លោកអ្នកឲ្យបានខ្ជាប់ខ្ជួនអញ្ចឹងដែរ។ វាជាការប្រពៃណាស់ក្នុងការកំណត់គោលដៅឲ្យបានច្បាស់លាស់ដើម្បីសម្រេចបាននូវការសិក្សាព្រះបន្ទូលតាមពេលវេលាជាក់លាក់ណាមួយរៀងរាល់សប្តាហ៍ ហើយត្រូវប្រាកដថា លោកអ្នកនឹងសម្រេចគោលដៅនោះបាន។ ស្ដេចសាឡូម៉ូន បានលើកឡើងថា “ការដែលបានសំរេច តាមបំណងចិត្តនោះ មានរសផ្អែមដល់ព្រលឹងហើយ” (សុភាសិត ១៣:១៩) ហើយលោកអ្នកនឹងទទួលបានភាពពេញចិត្តនៅពេលដែលលោកអ្នកសម្រេចបំណងដែលបានគ្រោងទុកនោះ។

៤. **ចូរសូម**មិត្តភក្តិរបស់លោកអ្នកណាម្នាក់ ដើម្បីឲ្យគាត់ជួយលើកទឹកចិត្តលើគោលដៅនៃការសិក្សាព្រះគម្ពីរប្រចាំសប្តាហ៍របស់លោកអ្នក ហើយលោកអ្នកប្រហែលជាអាចចែកចាយនូវអ្វីដែលបានរៀនទៅកាន់គាត់ផងដែរ។

ហេតុអ្វីពេលនេះយើងត្រូវយកចិត្តទុកដាក់ទៅលើអត្តចរិត?

ការផ្តោតទៅលើអាកប្បកិរិយាខាងក្រៅ ហើយមិនអើពើទៅនឹងអាកប្បកិរិយាខាងក្នុងនោះគឺជាការងាយស្រួលណាស់។ ជាធម្មតាពួកយើងទទួលការហ្វឹកហ្វឺនគឺដើម្បីសមត្ថភាពរបស់យើង។ ប៉ុន្តែ ចុះចំណែកឯចិត្តនិងអត្តន័យដែលនៅក្នុងជម្រៅចិត្តយើងវិញនោះ? អត្តចរិតកើតចេញមកពីអាកប្បកិរិយាខាងក្នុង ហើយមានន័យថា “សីលធម៌ល្អ និងភាពរឹងប៉ឹង”*។ ព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ជីវិតយើងគឺ ទាក់ទងទាំងលក្ខណសម្បត្តិនៃការគោរពប្រតិបត្តិដល់ព្រះជាម្ចាស់ដែលចេញពីខាងក្នុងដួងចិត្ត និងអាកប្បកិរិយាខាងក្រៅផងដែរ។ នៅក្នុងវគ្គនេះយើងនឹងសិក្សាអំពីលក្ខណៈនៃអត្តចរិតប្រាំយ៉ាង៖

- ការត្រាស់ហៅចំពោះការរស់នៅប្រកបដោយផលផ្លែ
- សកម្មភាពនៃសេចក្តីស្រឡាញ់ដែលឥតពុតមាយា
- ភាពបរិសុទ្ធនៃជីវិត
- ភាពស្អាតស្អំក្នុងការរស់នៅ
- ការអភិវឌ្ឍអត្តចរិតក្នុងការរងទុក្ខ

* មកពី *Webster's New Collegiate Dictionary* (Springfield, MA: G. and C. Merriam Company, ឆ្នាំ១៩៧៤)។

“ *ការអនុវត្តដែលមិនសមស្របរបស់អ្នកជឿជាច្រើនបានចាក់ឫសយ៉ាងជ្រៅដោយសារតែស្ថានភាពនៃទំនោរដូចគ្នានេះ៖ សមត្ថភាពទាំងឡាយរបស់គេបានទទួលការហ្វឹកហ្វឺនយ៉ាងទូលំទូលាយស្របពេលដែលមានមនុស្សស្មានថា អត្តចរិតរបស់គេល្អគ្រប់គ្រាន់ហើយ។*

ប៊ៀល ស្រ្តុល (Bill Thrall)
អ្នកដឹកនាំក្នុងអង្គការ Leadership Catalyst, Inc.

ជំពូកទី

១

ការត្រាស់ហៅចំពោះការរស់នៅប្រកបដោយផលផ្លែ

មនុស្សជាច្រើនធ្វើការវាស់វែងពីផលផ្លែនៃជីវិតរបស់ពួកគេដោយផ្អែកទៅលើបរិមាណនៃទង្វើទាំងប៉ុន្មានរបស់ពួកគេ។ ប៉ុន្តែការនេះមិនបានផ្តល់នូវរូបភាពដ៏ជាក់លាក់ណាមួយនោះទេ។ ការដែលលោកអ្នកប្រព្រឹត្ត វាមិនសំខាន់ជាងការដែលថា លោកអ្នកជានរណា និងជាអ្វីនោះទេ។ ព្រះគម្ពីរសង្កត់ធ្ងន់ទៅលើ ការរស់នៅ និងអត្តចរិត ស្របពេលដែលលោកអ្នកចម្រើនឡើងកាន់តែដូចព្រះគ្រីស្ទ។

ការលូតលាស់នៅក្នុង ផលផ្លែខាងវិញ្ញាណ

១. សូមអានកណ្ឌគម្ពីរ យ៉ូហាន ១៥:១-៥
នៅត្រង់ចំណុចនេះ ព្រះយេស៊ូវបានបង្ហាញនូវការយល់ដឹងយ៉ាងជ្រាលជ្រៅស្តីពីរឿងនៃការបង្កើតផលផ្លែខាងវិញ្ញាណ។

ក) នៅក្នុងភាពស្រដៀងគ្នានេះ តើនរណាជាគល់ ហើយនរណាជាខ្នែង?

ខ) ហេតុអ្វីបានខ្នែងត្រូវការគល់?

គ) សូមពន្យល់អត្ថន័យនៃឃ្លា "នៅជាប់ក្នុងព្រះគ្រីស្ទ"។

> *ប្រសិនបើព្រះគ្រីស្ទគង់នៅក្នុងយើង ហើយគ្រប់គ្រងលើបុគ្គលិកលក្ខណៈរបស់យើង នោះយើងនឹងទុកនូវទីសម្គាល់ដ៏រុងរឿងរបស់ព្រះជាម្ចាស់ដល់ជីវិតមនុស្សទាំងឡាយដែលមានការប៉ះពាល់ចិត្តដោយសារទង្វើរបស់យើង។ នោះគឺមិនមែនដោយសារលក្ខណៈដ៏គួរឲ្យស្រឡាញ់របស់យើងនោះទេ ប៉ុន្តែគឺដោយសារតែលក្ខណៈរបស់ទ្រង់វិញ។*
>
> យូជីនា ប្រ៊ីយ (Eugenia Price)

២. សូមអានពីផលផ្លែខាងឯព្រះវិញ្ញាណនៅក្នុង កណ្ឌគម្ពីរ កាឡាទី ៥:២២-២៣។ បន្ទាប់មកសូមសរសេរចុះពីលក្ខណសម្បត្តិដែលព្រះជាម្ចាស់សព្វព្រះហឫទ័យបណ្ដុះនៅក្នុងជីវិតរបស់លោកអ្នក ហើយសរសេរពីអត្ថន័យខ្លីៗនៃផលផ្លែនីមួយៗ។

ផលផ្លែខាងឯព្រះវិញ្ញាណ	អត្ថន័យខ្លីៗនៃផលផ្លែ
១.	
២.	
៣.	
៤.	
៥.	
៦.	
៧.	
៨.	
៩.	

៣. នៅក្នុងសេចក្ដីអធិប្បាយរបស់ព្រះយេស៊ូវនៅលើភ្នំ ទ្រង់បានបើកសម្ដែង ពីគុណសម្បត្តិនៃអត្តចរិតគ្រឹះប្រាំបីយ៉ាងសម្រាប់ការរស់នៅក្នុងជីវិត ដែលពេញបរិបូរណ៍ និងមានអំណរ។ សូមសរសេរចុះពីការប្រទានពរ ដែលព្រះយេស៊ូវបានសន្យាចំពោះគុណសម្បត្តិនៃអត្តចរិតនីមួយៗ (ម៉ាថាយ ៥:៣-១២)។

អ្នកទទួលព្រះពរ	សេចក្ដីសន្យារបស់ព្រះយេស៊ូវ
១. កំសត់ខាងវិញ្ញាណ (ខ៣)	
២. យំសោក (ខ៤)	
៣. ស្លូតត្រង់ (ខ៥)	
៤. ស្រេកឃ្លាននូវសេចក្ដីសុចរិត (ខ៦)	
៥. មេត្តាករុណា (ខ៧)	
៦. ចិត្តបរិសុទ្ធ (ខ៨)	
៧. អ្នកផ្សះផ្សា (ខ៩)	
៨. ត្រូវគេបៀតបៀនដោយព្រោះសេចក្ដី សុចរិត (ខ១០-១១)	

៤. ដោយសារព្រះវិញ្ញាណបរិសុទ្ធកំពុងតែអភិវឌ្ឍផលផ្លែរបស់ទ្រង់នៅក្នុង អត្តចរិតរបស់លោកអ្នក តើការនោះនឹងបំផ្លាស់បំប្រែជីវិតរស់នៅរបស់ លោកអ្នកយ៉ាងដូចម្ដេច?

តើវានឹងប៉ះពាល់ដល់ទំនាក់ទំនងរបស់លោកអ្នកយ៉ាងដូចម្ដេច?

៥. សូមស្វែងរកភាពខុសគ្នារវាងមនុស្សពីរប្រភេទក្នុងកណ្ឌគម្ពីរ យេរេមា ១៧:៥-៨។

អ្នកដែលទុកចិត្តលើមនុស្ស	អ្នកដែលទុកចិត្តលើព្រះជាម្ចាស់

៦. សូមគិតទៅមើលថា ជាធម្មតាតើលោកអ្នកទុកចិត្តទៅលើនរណា ឬ អ្វីផ្សេងទៀត។ តើមានចំណុចណាមួយដែលលោកអ្នកគួរនឹងឈប់ទុកចិត្តលើខ្លួនឯង ឬអ្នកដទៃ ដើម្បីនាំឲ្យលោកអ្នកវិលមកទុកចិត្តលើព្រះជាម្ចាស់វិញ? សូមពន្យល់៖

ការរីកចម្រើនខាងឯអត្តចរិត

៧. ព្រះបន្ទូលបានកត់សម្គាល់ពីផ្នែកមួយចំនួនដែលទាក់ទងនឹងជីវិតរបស់យើង ហើយផ្នែកទាំងនោះបង្ហាញពីអត្តចរិតដ៏ពិតរបស់យើង។ តើផ្នែកណាខ្លះដែលទាក់ទងទៅនឹងជីវិតរបស់យើង?

ភីលីព ៤:៨

កូល៉ុស ៤:៦

១ពេត្រុស ២:១២

អេភេសូរ ៤:៣១-៣២

៨. តើស្ថានភាពនៅក្នុងចិត្តរបស់យើងអាចជះឥទ្ធិពលដល់ផ្នែកផ្សេងទៀតនៃជីវិតរបស់យើងដោយរបៀបណា? (លូកា ៦:៤៥)

៩. តើនឹងមានអ្វីកើតឡើងចំពោះជីវិត និងគំនិតរបស់លោកអ្នក នៅពេលដែលលោកអ្នករីកចម្រើនខាងឯអត្តចរិត? (អេភេសូរ ៤:២២-២៤)

១០. សូមអានកណ្ឌគម្ពីរ យ៉ាកុប ៣:១៣-១៨។

ក) តើប្រាជ្ញាមកពីព្រះជាម្ចាស់អាចជួយឲ្យយើងមានការលូតលាស់ផ្នែកអត្តចរិតបានយ៉ាងដូចម្ដេច?

ខ) សូមស្វែងរកភាពខុសគ្នារវាងប្រាជ្ញាមកពីព្រះជាម្ចាស់ និងប្រាជ្ញាមកពីលោកីយ៍។ (ខ១៥-១៧)

ប្រាជ្ញាមកពីព្រះ	ប្រាជ្ញាមកពីលោកីយ៍

១១. សូមអានកណ្ឌគម្ពីរ ១ពេត្រុស ១:១៣-១៦។ តើអ្វីជាបំណង ព្រះហឫទ័យរបស់ ព្រះជាម្ចាស់ចំពោះយើង?

ខណៈពេលដែលព្រះជាម្ចាស់កំពុងតែផ្លាស់ប្រែអត្តចរិតរបស់លោកអ្នក ដើម្បីឲ្យកាន់តែដូចព្រះគ្រីស្ទនោះ តើមានវិធីសាស្ត្រជាក់ស្ដែងណាខ្លះ នៅក្នុងបទគម្ពីរដែលបានលើកឡើងនេះ ដែលអាចជួយឲ្យលោកអ្នក មានអត្តចរិតកាន់តែដូចព្រះគ្រីស្ទតាមព្រះហឫទ័យទ្រង់?

១២. សូមធ្វើការឆ្លុះបញ្ចាំងនៅត្រង់នេះបន្តិច។ តើលោកអ្នកធ្លាប់បាន ព្យាយាមផ្លាស់ប្ដូរអត្តចរិតផ្ទាល់ខ្លួនរបស់លោកអ្នកដោយមិនមានជំនួយ និងព្រះគុណពីព្រះជាម្ចាស់ដែរឬទេ? តើមានលទ្ធផលអ្វីខ្លះដែលបាន កើតឡើងនៅពេលនោះ?

១៣. សូមអាន ហើយធ្វើការសញ្ជឹងគិតទៅលើកណ្ឌគម្ពីរ ២ពេត្រុស ១:១-៨។ ព្រះបន្ទូលត្រង់ចំណុចនេះបានបង្ហាញចេញនូវគន្លឹះក្នុងការរីកចម្រើនផ្នែកអត្តចរិត។

ក) សូមសរសេរចុះនូវការមួយចំនួនដែលព្រះជាម្ចាស់បានប្រទានមកដើម្បីជួយលោកអ្នកឲ្យមានការរីកចម្រើនខាងផ្នែកអត្តចរិត (ខ៣-៤)។

ខ) សូមពន្យល់ត្រួសៗពីលក្ខណសម្បត្តិដែលបានលើកឡើងនៅក្នុង ខ៥-៧។

គ) ស្របពេលដែលអត្តចរិតរបស់លោកអ្នកបានចម្រើនឡើងនៅក្នុងលក្ខណសម្បត្តិទាំងនេះ តើការរីកចម្រើននៃលក្ខណសម្បត្តិទាំងនេះនឹងលើកកិត្តិយសដល់ព្រះជាម្ចាស់ ហើយជួយលោកអ្នកបានយ៉ាងដូចម្តេច?

ឃ) តើអំណាចរបស់ព្រះជាម្ចាស់បាន
ផ្លាស់ប្តូរអត្តចរិតរបស់លោកអ្នកយ៉ាង
ដូចម្តេចខ្លះ?



ង) សូមព្យាយាមកត់សម្គាល់ថា តើព្រះវិញ្ញាណបរិសុទ្ធកំពុងតែផ្តោតការយកចិត្តទុកដាក់ក្នុងការផ្លាស់ប្រែលក្ខណសម្បត្តិមួយណាក្នុងជីវិតរបស់លោកអ្នក។ ជាមួយនឹងជំនួយមកពីព្រះជាម្ចាស់ តើមានជំហានណាមួយដែលលោកអ្នកអាចអនុវត្តដើម្បីឲ្យបានកាន់តែដូចអង្គព្រះគ្រីស្ទ ក្នុងការបង្ហាញនូវគុណសម្បត្តិដែលលោកអ្នកបានលើកឡើងនោះ?

ជំហានក្នុងការគិត៖

ជំហានក្នុងការនិយាយស្តី៖

ជំហានក្នុងការប្រព្រឹត្តៈ

ការលូតលាស់ក្នុងសេចក្តីអំណរនៃការរស់នៅដ៏បរិសុទ្ធ

១៤. សូមអានកណ្ឌគម្ពីរ ភីលីព ៣:៤-១៤។
សាវ័កប៉ុលបានដកបទពិសោធន៍ពីសេចក្តីអំណរយ៉ាងជ្រាលជ្រៅនៅក្នុងដំណើរនៃការផ្លាស់ប្រែដោយសារព្រះគុណ។

ក) សូមសរសេរចុះនូវអាកប្បកិរិយា និងគំរូថ្មីៗមួយចំនួនរបស់សាវ័កប៉ុលដែលមានភាពខុសគ្នាទៅនឹងលក្ខណៈពីជីវិតមុនរបស់គាត់។

អាកប្បកិរិយានិងគំរូចាស់(ខ៤-៧)	អាកប្បកិរិយានិងគំរូថ្មី(ខ៧-១៤)
១. ទុកចិត្តខាងសាច់ឈាម	
២. អ្នកដឹកនាំសាសនា	
៣. បៀតបៀនដល់ក្រុមជំនុំ	
៤. ក្នុងក្រឹត្យវិន័យ នោះគ្មានទោសសោះ	
៥. រាប់ការទាំងអស់នោះថាជាប្រយោជន៍ដល់ខ្លួន	

ខ) សូមមើលទៅលើ ខ១៣ ម្ដងទៀត។ សាវ័កប៉ុលបានបោះបង់ចោល នូវការមួយចំនួនដែលពីមុនគាត់បានទុកចិត្តថា អាចជួយឲ្យគាត់មានជីវិតបរិសុទ្ធ។ តើមានការណាខ្លះដែលលោកអ្នកកំពុងតែពឹងផ្អែកលើវា ហើយលោកអ្នកគួរតែបោះបង់វាចោល?

គ) តើមានអ្វីខ្លះដែលលោកអ្នករំពឹងថានឹងទទួលបាន នៅថ្ងៃអនាគត? (ខ១៤)

> *ភាពខុសគ្នារវាងរបៀបដែលព្រះជាម្ចាស់ផ្លាស់ប្រែ និងប្ដូរចិត្តមនុស្ស និងរបៀបដែលយើងទាំងអស់គ្នាធ្វើនោះ គឺខុសគ្នាឆ្ងាយណាស់។ យើងផ្ដោតទៅលើសកម្មភាពផ្សេងៗ តែព្រះជាម្ចាស់ផ្ដោតមកលើយើងរាល់គ្នា។ យើងធ្វើពីខាងក្រៅចូលទៅខាងក្នុង តែព្រះជាម្ចាស់ធ្វើពីខាងក្នុងចេញមកខាងក្រៅ។ យើងខំព្យាយាមឲ្យព្រះជាម្ចាស់វិញទ្រង់បំផ្លាស់បំប្រែ។*
>
> រីឆាត ហ្វូស្ទឺរ (Richard Foster)
> ដកស្រង់ចេញពីសៀវភៅ *Devotional Classics*

១៥. ទោះបើសាវ័កប៉ុលស្ថិតនៅក្នុងបញ្ហា និងការឈឺចាប់យ៉ាងណាក្តី តើព្រះគុណរបស់ព្រះជាម្ចាស់បានជួយគាត់ក្នុងការលូតលាស់ផ្នែកអត្តចរិតបានយ៉ាងដូចម្តេច? (២កូរិនថូស១២:៧-៩)

តើព្រះជាម្ចាស់បានប្រើសេចក្តីវេទនាដោយរបៀបណា ដើម្បីអភិវឌ្ឍផ្នែកមួយចំនួននៃអត្តចរិតរបស់លោកអ្នក?

១៦. សូមអានកណ្ឌគម្ពីរ យ៉ូហាន ១៥:១១-១៦; ១៦:២៤; ១៧:១៣។ ដោយយោងតាមខគម្ពីរទាំងនេះ តើមានអ្វីខ្លះដែលធ្វើឲ្យអំណររបស់យើងកាន់តែចម្រើនឡើង?

តើអ្វីជាគន្លឹះដើម្បីឲ្យបានពេញដោយសេចក្ដីអំណរ? (ទំនុកដំកើង ១៦:១១)

១៧. ចំពោះលោកអ្នក តើជីវិតដែលពេញដោយអំណរមានលក្ខណៈដូចម្ដេច? តើលោកអ្នកធ្លាប់បានជួបនរណាម្នាក់ដែលពេញដោយអំណរ ប៉ុន្តែមានការយំសោកដែរឬទេ? សូមពន្យល់៖

១៨. តើព្រះយេស៊ូវបានសន្យាអ្វីខ្លះចំពោះអស់អ្នកដែលបានលះបង់អ្វីៗគ្រប់យ៉ាង ដើម្បីដើរតាមទ្រង់នោះ? (លូកា ១៨:២៩-៣០)

តើអ្វីទៅជាការឆ្លើយតបរបស់លោកអ្នកចំពោះការទទួលយកនូវសេចក្តីសន្យានេះ ទាំងសម្រាប់ពេលបច្ចុប្បន្ន និងពេលអនាគតនៅឯស្ថានសួគ៌?

អ្វីដែលយើងបានរៀនរហូតមកដល់ពេលនេះ គឺមិនមែនជាការងាយស្រួលនោះទេ ស្របពេលដែលសាច់ឈាម និងសារជាតិជាមនុស្សរបស់យើង នៅប្រឆាំងនឹងការរីកចម្រើននោះ។ យើងប្រហែលជាចង់រីកចម្រើនដោយកម្លាំងរបស់យើងផ្ទាល់។ ប៉ុន្តែទំនុកចិត្តរបស់យើងពឹងផ្អែកទៅលើការធានារ៉ាប់រងដែលព្រះជាម្ចាស់បានធ្វើការនៅក្នុងយើង ដើម្បីធ្វើឲ្យយើងមានភាពពេញវ័យក្នុងជំនឿ។ នៅក្នុងសេចក្តីមេត្តាករុណារបស់ទ្រង់ ព្រះជាម្ចាស់ដ៏បរិសុទ្ធរបស់យើងមិនបញ្ចេញសេចក្តីក្រោធរបស់ទ្រង់ដែលយើងសមនឹងទទួលនោះឡើយ។

ទ្រង់នឹងប្រទានឲ្យយើងនូវអស់ទាំងព្រះគុណដែលយើងត្រូវការយ៉ាងបរិបូរណ៍នៅក្នុងព្រះគ្រីស្ទ មិនមែនត្រឹមតែជាប្រយោជន៍ចំពោះជីវិតដ៏អស់កល្បប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាប្រយោជន៍ចំពោះជីវិតរស់នៅប្រចាំថ្ងៃរបស់យើងផងដែរ។

សំណេរខគម្ពីរមួយសម្រាប់សញ្ជឹងគិត និងការទន្ទេញចាំមាត់

យ៉ូហាន ១៥:៥

ខ្ញុំជាគល់ អ្នករាល់គ្នាជាខ្នែង អ្នកណាដែលនៅជាប់នឹងខ្ញុំ ហើយខ្ញុំជាប់នឹងអ្នកនោះ នោះទើបនឹងបង្កើតផលឡើងជាច្រើន ដ្បិតបើដាច់ពីខ្ញុំចេញ នោះអ្នករាល់គ្នាពុំអាចនឹងធ្វើអ្វីបានទេ

យ៉ូហាន ១៥:៥

សៀវភៅកំណត់ហេតុរបស់ខ្ញុំ

សូមសរសេរអំពីអត្តចរិតរបស់លោកអ្នកទៅកាន់ព្រះជាម្ចាស់។ បន្ទាប់មកសូមពណ៌នាពីអ្វីដែលលោកអ្នកឃើញនៅក្នុងអត្តចរិតរបស់លោកអ្នក និងពីរបៀបដែលលោកអ្នកចង់ឲ្យមានការរីកចម្រើនផ្នែកអត្តចរិត។

ចំណុចគួរចងចាំ

សូមសរសេរបន្ថែមមួយឬពីរឃ្លាដាក់នៅចុងឃ្លាខាងក្រោមនេះដើម្បីសង្ខេបនូវចំណុចសំខាន់ៗដែលលោកអ្នកបានរៀនពីផ្នែកនីមួយៗនៅក្នុងជំពូកនេះ។

ការលូតលាស់នៅក្នុងផលផ្លែខាងវិញ្ញាណ

ព្រះជាម្ចាស់សព្វព្រះហឫទ័យចម្រើននូវលក្ខណសម្បត្តិនៃអត្តចរិតដែលដូចទៅនឹងព្រះគ្រីស្ទក្នុងជីវិតយើង ទុកជាលទ្ធផលមួយនៃទំនាក់ទំនងរបស់យើងជាមួយនឹងព្រះគ្រីស្ទ។

ការលូតលាស់ខាងអត្តចរិត

ការលូតលាស់ផ្នែកអត្តចរិត គឺមានការជាប់ទាក់ទងទៅនឹង គំនិត ពាក្យសម្ដី ការប្រព្រឹត្ត និងមនោសញ្ចេតនា។

ការលូតលាស់ក្នុងសេចក្ដីអំណរនៃការរស់នៅដ៏បរិសុទ្ធ

ព្រះគុណរបស់ព្រះជាម្ចាស់ជួយឲ្យយើងមានអំណរ និងលូតលាស់ផ្នែកអត្តចរិត ទោះបើយើងស្ថិតក្នុងទុក្ខលំបាក និងភាពឈឺចាប់យ៉ាងណាក៏ដោយ។

ការចូលឲ្យបានស៊ីជម្រៅ

ក្នុងពួកអ្នករាល់គ្នា បើមានអ្នកណាមានប្រាជ្ញា និងយោបល់ ត្រូវឲ្យអ្នកនោះសំដែងចេញជាកិរិយាល្អ ដោយសារការដែលខ្លួនប្រព្រឹត្ត ដោយសេចក្ដីសុភាពនៃប្រាជ្ញាចុះ បើមានសេចក្ដីច្រណែនដ៏ជូរល្វីង និងសេចក្ដីគំនុំក្នុងចិត្ត នោះកុំឲ្យអួតខ្លួន ឬកុហកទទឹងនឹងសេចក្ដីពិតឡើយ ប្រាជ្ញាយ៉ាងនោះមិនមែនមកពីស្ថានលើទេ គឺជារបស់ផងលោកីយ៍នេះ ហើយក៏ខាងសាច់ឈាម និងខាងអារក្សវិញទេតើ ដ្បិតកន្លែងណាដែលមានសេចក្ដីច្រណែន និងសេចក្ដីគំនុំ នោះក៏មានវឹកវរ និងសេចក្ដីអាក្រក់គ្រប់យ៉ាងដែរ តែប្រាជ្ញាដែលមកពីស្ថានលើ នោះមុនដំបូងហៅថាបរិសុទ្ធ រួចមកមានមេត្រីចិត្ត សេចក្ដីសំឡូត ចិត្តទន់ ក៏ពេញដោយសេចក្ដីមេត្តាករុណា និងផលល្អ ឥតរើសមុខ ហើយឥតពុតមាយាផង រីឯផលនៃសេចក្ដីសុចរិត នោះបានព្រោះចុះដោយសេចក្ដីមេត្រី សំរាប់ពួកអ្នកដែលរកសេចក្ដីមេត្រីនោះឯង (យ៉ាកុប ៣:១៣-១៨)។

កណ្ឌគម្ពីរសុភាសិតបានផ្តល់ឲ្យយើងនូវការយល់ដឹងយ៉ាងស៊ីជម្រៅដែលទាក់ទងទៅនឹងការរីកចម្រើនផ្នែកអត្តចរិត ជាពិសេស៖

សំរាប់ឲ្យបានស្គាល់ប្រាជ្ញា និងសេចក្តីប្រៀនប្រដៅ ហើយឲ្យបានយល់អស់ទាំងសេចក្តីដែលត្រូវខាងយោបល់ (សុភាសិត ១:២)។

វាជាការល្អបើលោកអ្នកអានកណ្ឌគម្ពីរសុភាសិតទាំងមូល មួយជំពូកក្នុងមួយថ្ងៃ ក្នុងរយៈពេលមួយខែ។ ពេលដែលលោកអ្នកអាន សូមកត់ត្រាចូលទៅក្នុងសៀវភៅកំណត់ហេតុរបស់លោកអ្នកអំពីអត្តចរិតនៃមនុស្សដែលមានប្រាជ្ញា និងចេះកោតខ្លាចព្រះជាម្ចាស់។ លោកអ្នកអាចធ្វើជាតារាងមួយផ្សេងទៀតនៅជាប់គ្នានឹងតារាងមុនដែលបញ្ជាក់អំពីភាពផ្ទុយគ្នានៃប្រាជ្ញាដែលមកពីព្រះជាម្ចាស់ ជាមួយនឹងភាពល្ងីល្ងើនៃប្រាជ្ញាដែលមកពីលោកីយ៍។

ជំពូកទី

៣

សកម្មភាពនៃសេចក្តីស្រឡាញ់ដែលឥតពុតមាយា

" *ពាក្យថាព្រះគុណមានន័យថា គ្មានការណាមួយសោះឡើយ ដែលខ្ញុំអាចធ្វើឡើង ដើម្បីឲ្យព្រះជាម្ចាស់កាន់តែស្រឡាញ់ខ្ញុំជាងពេលនេះ ហើយក៏មិនមានការណាមួយដែលខ្ញុំអាចធ្វើឡើងដើម្បីឲ្យព្រះជាម្ចាស់ស្រឡាញ់ខ្ញុំតិចជាងពេលនេះដែរ។ គឺមានន័យថា ទោះបីជាខ្ញុំសមតែទទួលនូវអ្វីដែលផ្ទុយពីសេចក្តីស្រឡាញ់នោះក៏ដោយ ក៏ព្រះជាម្ចាស់នៅតែអញ្ជើញខ្ញុំឲ្យចូលទៅក្នុងគ្រួសាររបស់ទ្រង់ដែរ។*

ភីលីព យេនស៊ី (Philip Yancey)
ដកស្រង់ចេញពីសៀវភៅ *What's So Amazing About Grace?*

ដូចម្ដេចដែលហៅថាសេចក្ដីស្រឡាញ់ឥតពុតមាយា?

១. តើព្រះយេស៊ូវបានសម្ដែងពីសេចក្ដីស្រឡាញ់ដ៏អស្ចារ្យបំផុតយ៉ាងដូចម្ដេច? (យ៉ូហាន ១៥:១២-១៤)

២. តើសេចក្ដីស្រឡាញ់ដ៏ពិតមានលក្ខណៈដូចម្ដេចខ្លះ? (១កូរិនថូស ១៣:៤-៨)

សេចក្ដីស្រឡាញ់មានដូចជា	សេចក្ដីស្រឡាញ់មិនមានដូចជា

តើបុគ្គលម្នាក់នឹងមានប្រតិកម្មដូចម្តេច នៅពេលដែលគាត់ទទួលបានសេចក្តីស្រឡាញ់ដ៏ពិតប្រាកដនោះ?

៣. សូមអានកណ្ឌគម្ពីរ ១យ៉ូហាន ៤:៨-២១ ដោយយកចិត្តទុកដាក់៖

ក) តើព្រះជាម្ចាស់បានធ្វើអ្វីខ្លះ ដើម្បីសម្តែងពីសេចក្តីស្រឡាញ់របស់ទ្រង់ដល់យើងរាល់គ្នា? (ខ៩-១០)

ខ) តើយើងបានធ្វើអ្វី ដើម្បីឲ្យសមនឹងទទួលបាននូវសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់?

គ) ហេតុអ្វីបានជាយើងគួរតែស្រឡាញ់គ្នាទៅវិញទៅមក? (ខ១១, ១៩)

ឃ) តើសេចក្ដីភ័យខ្លាចមានឥទ្ធិពលដូចម្ដេចចំពោះសេចក្ដីស្រឡាញ់ ហើយសេចក្ដីស្រឡាញ់មានឥទ្ធិពលដូចម្ដេចចំពោះសេចក្ដីភ័យខ្លាច? (ខ១៨)

៤. សូមពិចារណាទៅលើប្រយោគខាងក្រោមទាំងនេះ៖ សូមសរសេរ (ព) បើលោកអ្នកយល់ព្រម ឬសរសេរ (ម) បើមិនយល់ព្រម

___សេចក្ដីស្រឡាញ់គឺជាការប្រព្រឹត្តចេញមក មិនមែនជាអារម្មណ៍នោះទេ។

___ប្រសិនបើខ្ញុំបានប្រគល់សេចក្ដីស្រឡាញ់ដល់គេគ្រប់គ្រាន់ហើយ ដូច្នេះខ្ញុំមិនចាំបាច់ទទួលសេចក្ដីស្រឡាញ់ទេ។

___ព្រះជាម្ចាស់គឺជាសេចក្ដីស្រឡាញ់ ទ្រង់កំពុងតែបង្ហាញសេចក្ដីស្រឡាញ់នោះ ហើយទ្រង់ស្រឡាញ់ព្រលឹងខ្ញុំដោយមានទាំងសេចក្ដីប្រចណ្ឌ មិនសព្វព្រះហឫទ័យឲ្យខ្ញុំស្រឡាញ់ព្រះណាផ្សេងទៀតឡើយ។

___មិនចាំបាច់ឲ្យខ្ញុំចូលចិត្តអ្នកទេ ប៉ុន្តែខ្ញុំចាំបាច់ត្រូវតែស្រឡាញ់អ្នក។.

___សេចក្ដីទុកចិត្តមានសារៈសំខាន់ទាំងក្នុងការប្រគល់ និងទទួលនូវសេចក្ដីស្រឡាញ់។

“ *បើមានមនុស្សពីរនាក់ស្រឡាញ់គ្នា ហើយមានម្នាក់ដែលមានសេចក្ដីស្រឡាញ់ខ្លាំងជាងម្នាក់ទៀត ដូច្នេះសូមឲ្យម្នាក់ដែលស្រឡាញ់ខ្លាំងជាងនោះគឺជារូបខ្ញុំ។*

មិនស្គាល់អ្នកនិពន្ធ

សេចក្តីស្រឡាញ់ដែល គ្មានភាពអាត្មានិយម

មនុស្សជាច្រើនបានរៀនតែពីការរស់នៅជាមួយគ្នាដែលគិតតែពីខ្លួនឯងប៉ុណ្ណោះ៖ ពួកគេនិយាយថា "ប្រសិនបើអ្នកធ្វើតួនាទីអ្នក ខ្ញុំនឹងធ្វើតួនាទីខ្ញុំ"។ ការឲ្យដោយមានលក្ខខណ្ឌប្រភេទនេះ មិនមែនជាសេចក្តីស្រឡាញ់ដ៏ពិតនោះទេ។ ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យយើងនិយាយថា "ទោះបីជាខ្ញុំមិនបានទទួលអ្វីសោះមកវិញក៏ដោយ ក៏ខ្ញុំនៅតែស្រឡាញ់អ្នក" ព្រះជាម្ចាស់បង្កើតឲ្យមានសេចក្តីស្រឡាញ់ និងការឲ្យដែលមិនគិតពីខ្លួនឯងនៅក្នុងអាកប្បកិរិយា និងការប្រព្រឹត្តរបស់យើង។ ប៉ុន្តែ មិនមែនគ្រាន់តែមានការនេះមួយហើយគ្រប់គ្រាន់នោះឡើយ ដើម្បីឲ្យយើងចេះស្រឡាញ់ដោយគ្មានភាពអាត្មានិយម យើងដាច់ខាតត្រូវតែមានកម្លាំងគ្រប់គ្រាន់ និងពេញលេញដើម្បីស្រឡាញ់អ្នកដទៃ។ សេចក្តីស្រឡាញ់បែបនេះកើតចេញមកពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដែលបំពេញយើងឡើង ហើយឲ្យយើងអាចស្រឡាញ់ដល់អ្នកដទៃទៀតដោយគ្មានភាពអាត្មានិយម។

៥. តើអ្នកដើរតាមព្រះយេស៊ូវគួរស្រឡាញ់អ្នកណា?

ចោទិយកថា ៦:៥

លូកា ៦:២៧

១ពេត្រុស ៤:៨

៦. សូមអានកណ្ឌគម្ពីរ យ៉ូហាន ១៣:៣៤-៣៥។ តាមការយល់ឃើញរបស់លោកអ្នកសូមគិតទៅមើលថា ហេតុអ្វីបានជាព្រះយេស៊ូវធ្វើការសង្កត់ធ្ងន់ទៅលើការបង្ហាញពីសេចក្តីស្រឡាញ់?

៧. ព្រះជាម្ចាស់បានបង្កើតយើងឲ្យមានតម្រូវការយ៉ាងត្រឹមត្រូវ។ សូមអានកណ្ឌគម្ពីរ ១យ៉ូហាន ៣:១៦-១៨។ តើលោកអ្នកយល់ថា ការស្រឡាញ់មនុស្ស និងការបំពេញនូវតម្រូវការរបស់ពួកគេមានទំនាក់ទំនងគ្នាយ៉ាងដូចម្ដេច?

ហេតុអ្វីបានជាយើងគួរអនុញ្ញាតឲ្យអ្នកដទៃបំពេញតម្រូវការរបស់យើង ដោយការទទួលសេចក្ដីស្រឡាញ់ពីពួកគេនោះ?

> *ការបន្ទាបខ្លួនមានន័យថា លោកអ្នកទុកចិត្តលើព្រះជាម្ចាស់ និងអ្នកដទៃទៀតដែលនៅជាមួយលោកអ្នក។*
>
> បៀល ស្រ្តល (Bill Thrall)
> អ្នកដឹកនាំក្នុងអង្គការ Leadership Catalyst, Inc.

សេចក្តីស្រឡាញ់ ដែលចេះបន្ទាបខ្លួន

៨. ការបន្ទាបខ្លួនបានមកពីការដែលមាន
ទស្សនៈត្រឹមត្រូវចំពោះព្រះជាម្ចាស់ និងចំពោះខ្លួនឯង។ វាទាក់ទងនឹងចំណុចមួយដែលថាលោកអ្នកនឹងទុកចិត្តអ្នកណា។ តើខគម្ពីរខាងក្រោមនេះ ប្រាប់លោកអ្នកអំពីការនេះយ៉ាងដូចម្តេច?

យេរេមា ៩:២៣-២៤

២កូរិនថូស ៣:៤-៥

ភីលីព ២:៣-៤

តើលោកអ្នកយល់យ៉ាងដូចម្ដេច ពីលក្ខណៈខុសគ្នារវាងអំនួត និង ទំនុកចិត្ត?

៩. សូមអានកណ្ឌគម្ពីរ ១ពេត្រុស ៥:៥-៦ ហើយពិចារណាពីរបៀបដែលព្រះជាម្ចាស់ឆ្លើយតបចំពោះបុគ្គលដែលចេះបន្ទាបខ្លួន។ បើតាមការយល់ឃើញរបស់លោកអ្នកសូមគិតទៅមើលថា តើហេតុអ្វីបានជាព្រះជាម្ចាស់ឲ្យតម្លៃខ្ពស់ទៅលើការបន្ទាបខ្លួននៃជីវិតរបស់បុគ្គលម្នាក់?

តើមានការអ្វីកើតឡើងចំពោះអ្នកដែលចេះបន្ទាបខ្លួន? សូមសរសេររឿងមួយពីជីវិតពិតដែលទាក់ទងនឹងនរណាម្នាក់ដែលបានបន្ទាបខ្លួន ហើយក្រោយមកបានទទួលការតម្កើងឡើង។

១០. សូមអានកណ្ឌគម្ពីរ រ៉ូម ១២:៣។

ក) តើលោកអ្នកយល់ថា លទ្ធផលនៃការឲ្យតម្លៃខ្លួនឯងខ្ពស់ពេកនោះនឹងទៅជាយ៉ាងណា?

ខ) តើលោកអ្នកយល់ថា លទ្ធផលនៃការទម្លាក់តម្លៃខ្លួនឯងទាបពេកនោះនឹងទៅជាយ៉ាងណា?

អស់ទាំងភាពខ្វល់ខ្វាយជាមួយការគិតទៅលើខ្លួនឯងគឺជាអំនួត។

អំនួត

ការឲ្យតម្លៃទៅលើខ្លួនឯងខ្ពស់ពេក “ព្រះជាម្ចាស់មិនអាចសម្រេចការណាមួយដោយគ្មានខ្ញុំបានឡើយ!”	ការឲ្យតម្លៃទៅលើខ្លួនឯងទាបពេក “ព្រះជាម្ចាស់មិនអាចសម្រេចការណាមួយតាមខ្ញុំបាននោះឡើយ!”

១១. សូមធ្វើការសញ្ជឹងគិតទៅលើគំរូនៃការបន្ទាបខ្លួន ការទុកចិត្ត ការស្រឡាញ់ ការស្តាប់បង្គាប់ និងការលើកតម្កើងរបស់ព្រះយេស៊ូវក្នុងកណ្ឌគម្ពីរ ភីលីព ២:៥-១១។

ក) តើព្រះយេស៊ូវទុកចិត្តលើនរណា?

ខ) តើព្រះយេស៊ូវបានបន្ទាបខ្លួនដោយរបៀបណា?

គ) តើមានអ្វីដែលជំរុញឲ្យព្រះហឫទ័យទ្រង់ស្រឡាញ់អ្នកដទៃដោយគ្មានភាពអាត្មានិយមយ៉ាងអស្ចារ្យដូច្នេះ?

ឃ) តើព្រះវរបិតាឆ្លើយតបចំពោះអាកប្បកិរិយារបស់ព្រះយេស៊ូវយ៉ាងដូចម្តេច?

១២. សូមសង្ខេបពីទំនាក់ទំនងដែលលោកអ្នកបានឃើញ រវាងសេចក្តីស្រឡាញ់ និងការបន្ទាបខ្លួន។

តើលោកអ្នកអាចបញ្ជាក់ឲ្យបានច្បាស់ពីការលូតលាស់ខាងឯសេចក្តីស្រឡាញ់ និងការបន្ទាបខ្លួនរបស់លោកអ្នកផ្ទាល់បានយ៉ាងដូចម្តេចខ្លះ?

សេចក្តីស្រឡាញ់តាមការនិយាយស្តី

១៣. តើពាក្យសម្តីដែលពេញដោយសេចក្តីស្រឡាញ់អាចបំពេញនូវតម្រូវការរបស់អ្នកដទៃបានយ៉ាងដូចម្តេច?

សុភាសិត ១២:២៥

អេសាយ ៥០:៤

អេភេសូរ ៤:២៩

កូល៉ុស ៤:៦

១៤. តើលោកអ្នកធ្លាប់មានគេស្រឡាញ់ដោយប្រើពាក្យសម្ដីល្អៗយ៉ាងណាខ្លះ? ជាធម្មតា តើលោកអ្នកឆ្លើយតបនឹងពាក្យរបស់គេនោះយ៉ាងដូចម្ដេចដែរ?

តើមាននរណាដែលលោកអ្នកអាចស្រឡាញ់បានតាមរយៈពាក្យសម្ដីល្អៗ ពាក្យលើកទឹកចិត្ត និងពាក្យកោតសរសើររបស់គេដែរទេ? តើលោកអ្នកអាចនិយាយអ្វីខ្លះទៅកាន់អ្នកនោះ?

១៥. តើព្រះជាម្ចាស់បានដាស់តឿនលោកអ្នកឲ្យជៀសវាងនូវអំពើបាបអ្វីខ្លះ?

សុភាសិត ១០:១៩

សុភាសិត ១៧:៩

សុភាសិត ២៧:២

ស្រឡាញ់តាមរយៈការប្រព្រឹត្តល្អ

សេចក្តីស្រឡាញ់មិនមែនគ្រាន់តែកើតឡើងទៅតាមអារម្មណ៍ខាងក្នុងប៉ុណ្ណោះទេប៉ុន្តែវាកើតឡើងតាមឆន្ទៈផងដែរ។ សេចក្តីស្រឡាញ់អាចស្តែងចេញឡើងតាមរយៈ ប្រសិទ្ធភាពរបស់វាទៅលើអស់អ្នកដែលបានទទួលសេចក្តីស្រឡាញ់នោះឯង។ ទោះបីជាការជួយដល់អ្នកដទៃដោយចិត្តសប្បុរសជាការពេញនិយមក៏ដោយ ក៏សេចក្តីស្រឡាញ់តាមរយៈទង្វើល្អ ជានិច្ចកាលមានភាពសក្តិសមសម្រាប់អ្នកដែលដើរតាមព្រះយេស៊ូវគ្រីស្ទដែរ។

១៦. តើសេចក្ដីសង្គ្រោះ និងការប្រព្រឹត្តល្អ មានទំនាក់ទំនងគ្នាយ៉ាងដូចម្ដេច? (អេភេសូរ ២:៨-១០)

តាមការយល់ឃើញរបស់លោកអ្នក សូមគិតទៅមើលថា ហេតុអ្វីបានជាអស់អ្នកដែលដើរតាមព្រះយេស៊ូវគួរតែធ្វើទង្វើល្អ?

១៧. តើអ្វីគួរតែជាការជំរុញទឹកចិត្តដ៏ចម្បងបំផុត ចំពោះសកម្មភាពទាំងឡាយរបស់លោកអ្នក? (១កូរិនថូស ១០:៣១)

១៨. ការរំឭកពីធាតុពិតនៃសេចក្តីស្រឡាញ់៖ សូមពិចារណាទៅលើកណ្ឌគម្ពីរ ១យ៉ូហាន ៣:១៧។ តើលោកអ្នកស្ម័គ្រចិត្តនឹងដោះអាវក្រៅលោកអ្នក ហើយឲ្យទៅនរណាម្នាក់ដែលត្រូវការដែរឬទេ? លោកអ្នកប្រហែលជាអាចគិតអំពីកាលៈទេសៈមួយ គឺនៅពេលដែលលោកអ្នកបានឃើញពីតម្រូវការរបស់អ្នកដទៃទៀត ប៉ុន្តែមិនបានជួយគេសោះ។ តើលោកអ្នកគួរធ្វើដូចម្តេច នៅពេលដែលមានឱកាសបែបនេះនៅពេលក្រោយទៀត?

១៩. តើលោកអ្នកគួរចងចាំនូវចំណុចលើកទឹកចិត្តណាខ្លះក្នុងការប្រព្រឹត្តល្អ?

កាឡាទី ៦:៩-១០

ទីតុស ៣:៨

កាលពីយូរណាស់មកហើយ មានទាហានវ័យក្មេងម្នាក់បានទូរស័ព្ទទៅឪពុកម្តាយរបស់គាត់ បន្ទាប់ពីឈប់ធ្វើជាទាហាន។ គាត់បានសុំការអនុញ្ញាតពីឪពុកម្តាយ ដើម្បីយកមិត្តសម្លាញ់របស់គាត់ម្នាក់ទៅផ្ទះជាមួយគាត់។ គាត់បាននិយាយថា "អ្នកម្តាយដឹងទេ មិត្តភក្តិរបស់ខ្ញុំម្នាក់មានរបួសធ្ងន់ណាស់នៅក្នុងសឹកសង្គ្រាម។ គាត់នៅសល់តែជើងម្ខាង ដៃម្ខាង ហើយមានភ្នែកតែមួយចំហៀងប៉ុណ្ណោះ"។

បន្ទាប់ពីមានការស្ងាត់មាត់មួយសន្ទុះមក ម្តាយគាត់បាននិយាយដោយការមិនពេញចិត្តថា «បាន....កូនប្រុស គាត់អាចស្នាក់នៅជាមួយពួកយើងមួយរយៈ» ទោះបីជាយ៉ាងនេះក្តី សំឡេងរបស់ម្តាយគាត់បានភ្ជាប់មកជាមួយនូវអត្ថន័យដែលគាត់មិនចង់ទទួលយកបន្ទុកថែរក្សាជនពិការដ៏ធ្ងន់ធ្ងរម្នាក់នេះក្នុងរយៈពេលដ៏យូរនោះទេ។

ពីរថ្ងៃក្រោយមក ពួកគាត់បានទទួលសារមួយថា កូនរបស់គាត់បានលោតសម្លាប់ខ្លួនពីលើសណ្ឋាគារមួយស្លាប់បាត់ទៅហើយ។ នៅពេលដែលគេយកសាកសពកូនប្រុសគាត់មកដើម្បីបញ្ចុះ ពេលនោះម្តាយគាត់ក៏មានការគ្រាំគ្រាចិត្តជាខ្លាំង ពេលដែលឃើញថា សពកូនរបស់គាត់មានជើងតែម្ខាង ដៃតែម្ខាង និងភ្នែកតែមួយចំហៀងប៉ុណ្ណោះ!

ការនឹកចាំពីការសន្ទនាចុងក្រោយរបស់ម្តាយគាត់នៅតែឮរងំក្នុងត្រចៀករបស់គាត់ ហើយជារឿយៗគាត់តែងតែយំ ហើយលើកឡើងថា៖ «ឱខ្លួនខ្ញុំអើយហេតុអ្វីមិនប្រយ័ត្នមាត់ ហើយនិយាយដោយគ្មានសេចក្តីស្រលាញ់សោះអញ្ចឹង? ប្រសិនបើខ្ញុំអាចយកពាក្យសំដីដ៏អាត្មានិយមទាំងអស់នោះត្រលប់មកវិញបានប្រហែលជាកូនខ្ញុំអាចរស់នៅជាមួយពួកយើងបានបន្តិចទៀតទៅហើយ ប៉ុន្តែឥឡូវវាហួសអស់ទៅហើយ!»

ហិនរី ជី. បស្ឆ៍ (Henry G. Bosch)*

---

* មកពី Henry G. Bosch, *Our Daily Bread* ថ្ងៃទី៧ ខែមិនា ឆ្នាំ ១៩៧៥។

សំណើខគម្ពីរមួយសម្រាប់
សញ្ជឹងគិត និងការទន្ទេញចាំមាត់

១កូរិនថូស ១៣:១៣

ឥឡូវនេះ នៅមានសេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់ ទាំង៣មុខនេះ តែសេចក្តីដែលវិសេសជាងគេ គឺជាសេចក្តីស្រឡាញ់

១កូរិនថូស ១៣:១៣

សៀវភៅកំណត់ហេតុរបស់ខ្ញុំ

អ្នកមានចិត្តស្រឡាញ់តែងតែអត់ធ្មត់ ជួយធុរៈគេ ហើយមិនចេះឈ្នានីសគេទេ។ អ្នកមានចិត្តស្រឡាញ់មិនវាយឫកខ្ពស់ មិនអួតបំប៉ោងឡើយ។ អ្នកមានចិត្តស្រឡាញ់មិនប្រព្រឹត្តអំពើថោកទាប មិនស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន មិនមួម៉ៅ មិនចងគំនុំ មិនអបអរនឹងអំពើទុច្ចរិតទេ តែរីករាយនឹងសេចក្ដីពិតវិញ។ អ្នកមានចិត្តស្រឡាញ់អត់ឱនអោយទាំងអស់ ជឿទាំងអស់ សង្ឃឹមទាំងអស់ ហើយទ្រាំទ្រទាំងអស់ (១កូរិនថូស ១៣:៤-៧)។

សូមសរសេរចុះពីរបៀបដែលលោកអ្នកចង់ឲ្យគេស្រឡាញ់ខ្លួន និងពីរបៀបដែលលោកអ្នកបង្ហាញសេចក្ដីស្រឡាញ់ដល់គេវិញ។

ចំណុចគួរចងចាំ

សូមសរសេរបន្ថែមមួយឬពីរល្បះដាក់នៅចុងឃ្លាខាងក្រោមនេះដើម្បីសង្ខេបនូវចំណុចសំខាន់ៗដែលលោកអ្នកបានរៀនពីផ្នែកនីមួយៗនៅក្នុងជំពូកនេះ។

ដូចម្តេចដែលហៅថាសេចក្តីស្រឡាញ់ឥតពុតមាយា?

ព្រះបន្ទូលបានសម្តែង ហើយនិងធ្វើការបង្ហាញឲ្យយើងឃើញពីសេចក្តីស្រឡាញ់ដ៏មិនចេះប្រែប្រួលរបស់ព្រះជាម្ចាស់។

សេចក្តីស្រឡាញ់ដែលគ្មានភាពអាត្មានិយម

សេចក្តីស្រឡាញ់គួរតែជាសញ្ញាសម្គាល់មួយរបស់យើងរាល់គ្នាក្នុងនាមជាអ្នកដើរតាមព្រះយេស៊ូវ។

សេចក្តីស្រឡាញ់ដែលចេះបន្ទាបខ្លួន

ភាពជឿទុកចិត្ត គឺជាចំណុចចាប់ផ្តើមដំបូងបំផុតនៃសេចក្តីស្រឡាញ់។

សេចក្ដីស្រឡាញ់តាមការនិយាយស្ដី

យើងធ្វើការបង្ហាញសេចក្ដីស្រឡាញ់តាមរយៈ ការនិយាយពាក្យសម្ដីពីរោះ និងការនិយាយពាក្យកោតសរសើរបស់យើង។

សេចក្ដីស្រឡាញ់តាមរយៈការធ្វើការល្អ

សកម្មភាពទាំងឡាយនឹងបង្ហាញពីសេចក្ដីស្រឡាញ់ដ៏ពិតប្រាកដរបស់យើង។

ការចូលឲ្យបានស៊ីជម្រៅ

បំណងចិត្តក្នុងការអត់ទោសដល់អ្នកដទៃ ការបង្ហាញសេចក្ដីមេត្តាករុណាទៅដល់ពួកគេ គឺជាអត្តចរិតនៃសេចក្ដីស្រឡាញ់ដ៏ជ្រាលជ្រៅមួយ។ តើចិត្តរបស់លោកអ្នកមានការពិបាកក្នុងការអត់ទោសដល់គេដែរឬទេ នៅពេលដែលគេមិនបានសុំអភ័យទោសពីលោកអ្នក? នោះហើយគឺជាពេលដ៏ល្អបំផុតសម្រាប់យើង ដើម្បីសម្ដែងពីសេចក្ដីមេត្តាករុណា និងការអភ័យទោសចំពោះអ្នកដទៃ។ ព្រះយេស៊ូវបានមានបន្ទូលនៅពេលដែលទ្រង់ជាប់នៅ ឈើឆ្កាងថា “ឱព្រះវរបិតាអើយ សូមអត់ទោសដល់អ្នកទាំងនេះផង ដ្បិតគេមិនដឹងជាគេធ្វើអ្វីទេ” (លូកា ២៣:៣៤)។ ព្រះយេស៊ូវបានប្រទានសេចក្ដីមេត្តាករុណាមិនមែនទាមទាររកភាពយុត្តិធម៌នោះទេ។ សូមធ្វើការសញ្ជឹងគិតទៅលើកណ្ឌគម្ពីរ ម៉ាថាយ ៦:១៤-១៥, ម៉ាថាយ ៧:១-៥ និងយ៉ាកុប ២:១២-១៣។ សូមសរសេរចុះពីគំនិតរបស់លោកអ្នកទៅលើការអត់ទោស ការថ្កោលទោស និងសេចក្ដីមេត្តាករុណា ហើយបញ្ជាក់ថាតើការទាំងអស់នេះមានការជាប់ទាក់ទងទៅនឹងការស្រឡាញ់ដល់អ្នកដទៃយ៉ាងដូចម្ដេច។

ជំពូកទី

៣

ភាពបរិសុទ្ធនៃជីវិត

ការរស់នៅតាមក្រមសីលធម៌នៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺមិនមានភាពងាយស្រួល ហើយក៏មិនមានការពេញនិយមនោះដែរ។ នៅលើលោកីយ៍នេះ មានមនុស្សជាច្រើនស្វែងរកសេរីភាពដើម្បីគេចពី ការទទួលខុសត្រូវផ្នែកសីលធម៌។ ចំពោះអស់អ្នកដើរតាមព្រះយេស៊ូវវិញ ពួកគេមានអភ័យឯកសិទ្ធិ និងកាតព្វកិច្ចក្នុងការរស់នៅដែលស្របតាមគុណតម្លៃនៃព្រះគម្ពីរ។ ស្របពេលដែលយើងអនុវត្តតាមព្រះគម្ពីរ នោះសេចក្តីទុកចិត្តរបស់យើងក្នុងសេចក្តីសប្បុរសរបស់ព្រះជាម្ចាស់នឹងមានការលូតលាស់ឡើង។ យើងអាចដកពិសោធន៍កាន់តែច្រើនអំពីបំណងព្រះហឫទ័យព្រះ “ដែលល្អ ស្រួលទទួល ហើយគ្រប់លក្ខណ៍ផង” (រ៉ូម ១២:២)។

ខ្នាតគំរូនៃព្រះជាម្ចាស់

១. សូមប្រើវចនានុក្រមដើម្បីឲ្យនិយមន័យនៃពាក្យ បរិសុទ្ធ។

២. តើព្រះជាម្ចាស់សន្យាយ៉ាងដូចម្តេចចំពោះអស់អ្នកដែលមានចិត្តបរិសុទ្ធ? (ទំនុកដំកើង ២៤:៣-៥, ម៉ាថាយ ៥:៨)

“ *កូនអើយ សូមផ្តោតចំណាប់អារម្មណ៍ជានិច្ចអំពីព្រះវត្តមាននៃព្រះជាម្ចាស់ដ៏វិសុទ្ធ និងអស្ចារ្យបំផុត ឲ្យបានជ្រាលជ្រៅក្នុងចិត្តរបស់កូនតាមដែលអាចធ្វើទៅបាន។ ទ្រង់នៅជិតៗគ្រែរបស់យើង នៅជិតៗផ្លូវរបស់យើង ហើយទ្រង់ពិនិត្យគ្រប់ទាំងការដែលយើងធ្វើ។ នៅពេលណាដែលកូនមានសេចក្តីល្បួងនាំឲ្យធ្លាក់ចូលទៅក្នុងអំពើបាបណាមួយ ឬក៏នាំឲ្យភ្លេចពីតួនាទីណាមួយ សូមផ្អាកបន្តិចហើយសួរខ្លួនឯងថា “តើឥឡូវនេះខ្ញុំហៀបនឹងធ្វើអ្វី? ព្រះជាម្ចាស់ទ្រង់ទតឃើញខ្ញុំគ្រប់ពេលវេលា”។*

ស៊ូសាណា វេស្លី (Susanna Wesley)
ទៅកាន់កូនប្រុសច្បងរបស់ គាត់ដែលមានឈ្មោះថា សែមយ៉ូអែល (Samuel)

៣. តើមានរឿងមិនគួរគប្បីណាខ្លះដែលយើងត្រូវប្រយ័ត្នប្រយែង? (អេភេសូរ ៥:៣-៥)

៤. ខ្នាតរបស់លោកីយ៍ខុសឆ្ងាយពីខ្នាតរបស់ព្រះជាម្ចាស់ទាំងស្រុង។ យោងតាមកណ្ឌគម្ពីរ ១យ៉ូហាន ២:១៥-១៦ តើខ្នាតរបស់លោកីយ៍នេះមានអ្វីខ្លះ? សូមសរសេរចុះ ហើយឲ្យនិយមន័យនៃខ្នាតទាំងនោះ។

ខ្នាត	និយមន័យ

៥. អត្ថបទនៅក្នុងសញ្ញាថ្មីមួយចំនួនបានបញ្ជាក់យ៉ាងច្បាស់អំពីអត្តចរិតទាំងឡាយនៃបុគ្គលម្នាក់ដែលមានទំនាក់ទំនងល្អចំពោះអ្នកដទៃ។ សូមអានកណ្ឌគម្ពីរ ១ធីម៉ូថេ ៥:១-២។

ក) តើយើងគួរប្រព្រឹត្តចំពោះអ្នកដទៃយ៉ាងដូចម្ដេច?

ខ) សូមសរសេរចុះនូវខ្នាតគំរូផ្នែកសីលធម៌ក្នុងព្រះគម្ពីរដែលលោកអ្នកគ្រាប់តាមស្ដីពីទំនាក់ទំនងជាមួយនឹងមនុស្សដែលមានភេទផ្ទុយពីលោកអ្នកឲ្យបានយ៉ាងតិចពីរ។

គ) តើលោកអ្នកមានទំនាក់ទំនងដែលលោកអ្នកត្រូវនាំយកមក ហើយស្របគ្នាទៅនឹងខ្នាតគំរូ និងអាកប្បកិរិយាទាំងនោះឬទេ? បើមាន តើលោកអ្នកគួរធ្វើដូចម្ដេច?

សារៈសំខាន់នៃភាពបរិសុទ្ធផ្ទាល់ខ្លួន

បើទោះជាមានការលើកឡើងជាច្រើនអំពីភាពបរិសុទ្ធផ្ទាល់ខ្លួនក៏ដោយ យើងនៅតែផ្តោតសំខាន់ជាពិសេសទៅលើភាពបរិសុទ្ធផ្នែកភេទ និងការកសាងទំនាក់ទំនងដែលជាព្រះហឫទ័យព្រះជាម្ចាស់រវាងបុរស និងស្ត្រី។

៦. តើព្រះជាម្ចាស់មានបំណងព្រះហឫទ័យដូចម្តេចចំពោះអាកប្បកិរិយារបស់យើង?

ម៉ាថាយ ៥:២៧-២៨

២កូរិនថូស ៧:១

១ថែស្សាឡូនីច ៤:៣-៨

សូមពណ៌នាពីការមួយចំនួនដែលលោកអ្នកបានដឹងនៅក្នុងជីវិតលោកអ្នកដែលអាចនាំឲ្យរូបកាយ ឬវិញ្ញាណរបស់លោកអ្នកទៅជាមិនស្អាត។

៧. តើព្រះជាម្ចាស់មានបន្ទូលដូចម្ដេច ពីអស់អ្នកដែលប្រព្រឹត្តតែសេចក្ដីស្មោកគ្រោក? (អេភេសូរ ៤:១៨-១៩)

៨. សូមសរសេរចុះពីហេតុផលមួយចំនួននៃអំពើអសីលធម៌ដែលយើងគួរចៀសវាង។ (១កូរិនថូស ៦:១៣-២០ និងសូមមើលលើតារាងនៅក្នុងផ្នែក **ការចូលឲ្យបានស៊ីជម្រៅ**នៅក្នុងជំពូកនេះ)

ខ១៣

ខ១៥

ខ១៦-១៧

ខ១៨

ខ១៩

ខ២០

៩. បន្ទាប់ពីព្រះជាម្ចាស់បានបង្កើតពិភពលោក និងមនុស្សប្រុសស្រីរួចមក ព្រះទ្រង់ទតគ្រប់ទាំងរបស់ដែលទ្រង់បានបង្កើតនោះ ក៏ឃើញថា ទាំងអស់ជាការល្អប្រពៃ (លោកុប្បត្តិ ១:៣១)។ តើមានហេតុផលអ្វីដែលនាំឲ្យមានភេទប្រុស និងភេទស្រី? (លោកុប្បត្តិ ១:២៧-២៨)

តើអំពើអសីលធម៌ផ្នែកកាមគុណអាចធ្វើឲ្យសេចក្តីល្អរបស់ព្រះជាម្ចាស់ក្នុងការបង្កើតភេទទាំងពីរទៅជាច្របូកច្របល់បានយ៉ាងដូចម្តេចខ្លះ?

១០. តើព្រះបន្ទូលបានចែងយ៉ាងដូចម្តេច ចំពោះការដោះសារពីទង្វើដែលប្រាសចាកសីលធម៌ខាងក្រោមនេះ?

ក) “ដោយសារតែគ្រប់គ្នាក៏ប្រព្រឹត្តយ៉ាងដូច្នេះដែរ នោះវាច្បាស់ជាមិនអីទេ” ។ (សូមអាន សុភាសិត ១៤:១២)

ខ) “ខ្ញុំគ្រាន់តែចង់រកឲ្យឃើញថា ការនេះវាល្អត្រឹមត្រូវសម្រាប់ខ្ញុំប៉ុណ្ណោះទេ”។ (សូមអាន សាស្តា ១១:៩)

គ) “ខ្ញុំមិនបានធ្វើឲ្យនរណាម្នាក់ទទួលការឈឺចាប់នោះទេ អញ្ចឹងវាមិនមានបញ្ហាអ្វីទេ”។ (សូមអាន លេវីវិន័យ ៥:១៧)

ឃ) “មិនមាននរណាមួយអាចដឹងពីទង្វើដែលខ្ញុំធ្វើទេឡើយ”។ (សូមអាន ហេព្រើរ ៤:១៣)

ង) “ខ្ញុំធ្វើតែម្តងនេះទៀតទេ”។ (សូមអាន កាឡាទី ៦:៧-៨)

ច) “ខ្ញុំពិតជាមិនបានប្រព្រឹត្តអ្វីទាំងអស់ គឺខ្ញុំគ្រាន់តែគិតក្នុងចិត្តប៉ុណ្ណោះ”។ (សូមអាន ម៉ាថាយ ៥:២៨)

ឆ) “ប្រសិនបើវាធ្វើឲ្យយើងមានភាពរីករាយមានន័យថា វាត្រឹមត្រូវហើយ”។ (សូមអាន ហេព្រើរ ១១:២៥)

គន្លងឆ្ពោះទៅរកភាពបរិសុទ្ធ

សូមកុំស្មានថា ការរក្សានូវភាពបរិសុទ្ធផ្នែកភេទទាំងការគិត និងការប្រព្រឹត្ត គឺជារឿងងាយស្រួលនោះឡើយ តាមពិតវាជាការពិបាកមែនទែន។ ប៉ុន្តែមិនមែនមានន័យថាវាមិនអាចធ្វើបាននោះទេ!

១១. តើជំហានដែលចាប់ផ្ដើមពីសេចក្ដីល្បួងឈានដល់ការធ្វើបាបមានអ្វីខ្លះ? (យ៉ាកុប ១:១៤-១៥)

១២. សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ៣:៦, ៨ និង យ៉ូស្វេ ៧:២១។ តើអត្ថបទទាំងពីរនេះមានលក្ខណៈស្រដៀងគ្នាត្រង់ចំណុចណាខ្លះ? សូមសរសេរចុះពីចំណុចដែលស្រដៀងគ្នានោះ។

	លោកុប្បត្តិ ៣:៦, ៨	យ៉ូស្វេ ៧:២១
ក) តើគេបានប្រើឃានវិញ្ញាណមួយណា?		
ខ) បន្ទាប់មកគេមានអារម្មណ៍យ៉ាងណា?		

គ) បន្ទាប់មកគេបាន ធ្វើអ្វី?		
ឃ) តើគេបានធ្វើអ្វី ជាមួយនឹងភស្តុតាង ដែលបញ្ជាក់ពីកំហុស របស់គេ?		

តើលោកអ្នកគិតថា គ្រប់ទាំងអំពើបាបកើតឡើងតាមគំរូខាងលើនេះដែរ ឬទេ? បើមែន ហេតុអ្វី? បើមិនមែន ហេតុអ្វី?

១៣. សូមគិតត្រង់ចំណុចនេះបន្តិច។ លោកីយ៍ដែលលោកអ្នកកំពុងតែ រស់នៅនាពេលបច្ចុប្បន្ននេះ នោះគឺពេញទៅដោយរូបភាព និងឱកាស ដែលទាក់ទងទៅនឹងរឿងរ៉ាវផ្នែកផ្លូវភេទ។ អញ្ចឹង តើលោកីយ៍នេះចង់ឲ្យ លោកអ្នកមានគំនិតយ៉ាងដូចម្ដេចទាក់ទងនឹងផ្នែកផ្លូវភេទ?

“*ការតយុទ្ធត្រូវតែមានជាដំរាប។ សេចក្តីល្បួងបានចូលទៅកាន់មនុស្ស ហើយនាំឲ្យគេធ្លាក់ក្នុងអំពើបាប ចាប់តាំងពីនៅក្នុងសួនច្បារអេដែនមកម្ល៉េះ។ អ្វីដែលធ្វើឲ្យបញ្ហាទៅជាការស្មុគស្មាញនោះគឺ សារជាតិដ៏អាក្រក់របស់អំពើអាសអាភាស។ អំពើអាសអាភាសគឺជារឿងសម្ងាត់ ហើយជាការបបោសអង្អែល វាបំពេញនូវការត្រេកត្រអាលពីធម្មជាតិនៃចំណង់មិនចេះឈប់ឈររបស់មនុស្សដោយសារតែ “ភ្នែកនៃមនុស្សក៏មិនចេះស្កប់ស្កល់”។ នៅពេលដែលយើងខិតខំតស៊ូព្យាយាមជាមួយនឹងការតយុទ្ធដើម្បីសីលធម៌ ហើយជាពិសេសនោះ ប្រសិនបើយើងបរាជ័យក្នុងការសាកល្បង នោះនិស្ស័យរបស់យើងគឺរត់គេចចេញ ហើយនិងលាក់បំពួន។ លោកអ័ដាម និងនាងអេវ៉ាក៏បានធ្វើយ៉ាងដូច្នោះដែរ ពួកគេព្យាយាមលាក់ខ្លួនពីព្រះជាម្ចាស់... ពួកគេព្យាយាមលាក់អំពើបាបរបស់ខ្លួនដែលប្រៀបបានដូចជាការលាក់បំពួនអំពើអាសអាភាសដែលនាំទៅរកភាពអាថ៌កំបាំងដ៏ស្មោកគ្រោកយ៉ាងដូច្នោះដែរ។*

លោក ក្រេក ហ្គ្រូស និង ម៉ែក ហ្វូស្ទ័រ (Craig Gross and Mike Foster)
ដកស្រង់ចេញពីសៀវភៅ *Questions You Can’t Ask Your Mama About Sex*

ដោយសារព្រះជាម្ចាស់មានបំណងព្រះហឫទ័យចង់ឲ្យយើងបានបរិសុទ្ធ តើការស្រឡាញ់ និងការគោរពឲ្យតម្លៃទៅលើភាពថ្លៃថ្នូរចំពោះមនុស្ស មានការជាប់ទាក់ទងទៅនឹងរឿងអាសអាភាសយ៉ាងដូចម្តេច?

១៤. មនុស្សយើងគ្រប់គ្នាគឺមានការយល់ឃើញ និងបទពិសោធន៍ខាងផ្នែកផ្លូវភេទខុសៗគ្នា មិនថាតាមរយៈជីវិតពិត តាមរយៈការមើលរូបអាសអាភាស ឬក៏រឿងផ្សេងៗទៀតនោះឡើយ។ ព្រះគម្ពីរបានបញ្ជាក់ប្រាប់យើងយ៉ាងច្បាស់ថា គ្មានអំពើបាបណាមួយដែលព្រះជាម្ចាស់ទ្រង់មិនអត់ទោសឲ្យនោះទេ ទោះបីជាអំពើបាបផ្នែកផ្លូវភេទក៏ដោយ។ ដោយយោងតាមបទគម្ពីរខាងក្រោមនេះ សូមសរសេរបង្ហើយឃ្លានេះ «ទោះបីជាខ្ញុំបានធ្វើអ្វីពីអតីតកាលក៏ដោយ ប្រសិនបើខ្ញុំប្រែចិត្តមែននោះ នោះព្រះជាម្ចាស់នឹងអត់ទោសឲ្យខ្ញុំជាមិនខាន ដោយសារតែ...»

ហេព្រើរ ៩:១៤

ហេព្រើរ ១០:១៩-២៣

១៥. តើលោកអ្នកធ្លាប់មានអារម្មណ៍ថាមិនបរិសុទ្ធ ឬក៏ស្មោកគ្រោកដែរឬទេ? ប្រសិនបើដូច្នោះមែន សូមពណ៌នានូវអារម្មណ៍នោះ។

ក) ឥឡូវសូមចំណាយពេលបន្តិច ហើយគិតមើល តើលោកអ្នកនឹងមានអារម្មណ៍យ៉ាងណា បើព្រះជាម្ចាស់សម្អាតលោកអ្នកឲ្យបានជ្រះថ្លានិងបរិសុទ្ធពីអំពើបាបផ្នែកផ្លូវភេទ។ តើលោកអ្នកមានអារម្មណ៍ថា លោកអ្នកសមនឹងទទួលសេចក្តីសន្យាពីការលាងសម្អាតនេះកម្រិតណា?

ខ) តើការអត់ទោសរបស់ព្រះជាម្ចាស់ធ្វើឲ្យលោកអ្នកមានអារម្មណ៍បែបណាខ្លះ?

១៦. សូមព្យាយាមបំភ្លេចពាក្យ “ឆ្មា”។ នៅពេលដែលលោកអ្នកបានភ្លេចវាហើយ សូមគូសក្នុងប្រអប់នេះ□។ តើលោកអ្នកអាចធ្វើវាបានឬទេ? នេះគឺជារបៀបដែលមនុស្សមួយចំនួនព្យាយាមគេចចេញពីភាពអសីលធម៌។ ពួកគេគិតថា ពួកគេគ្រាន់តែធ្វើមិនឲ្យខ្លួនឯងផ្ទាល់គិតអំពីវាប៉ុណ្ណោះ។ ប៉ុន្តែវាមិនអាចទៅរួចទេ ក្នុងការបំបាត់នូវគំនិតខុសឆ្គងដែលចេញពីចិត្តលោកអ្នក បើលោកអ្នកមិនដាក់សេចក្តីទុកចិត្តទៅលើព្រះជាម្ចាស់ ដើម្បីជួយលោកអ្នកឲ្យដាក់អ្វីដែលល្អជំនួសគំនិតអាក្រក់នោះ។

ក) តើព្រះជាម្ចាស់បានសន្យាយ៉ាងដូចម្តេច នៅពេលដែលយើងជួបនឹងសេចក្តីល្បួង? (១កូរិនថូស ១០:១៣)



ខ) សាវ័កប៉ុលបានមានប្រសាសន៍ថា យើងត្រូវតែ “ដោះចោលចេញ” នូវមនុស្សចាស់ហើយ “ប្រដាប់” នូវមនុស្សថ្មីវិញ (អេភេសូរ ៤:២២-២៤)។ អត្ថបទនេះបង្ហាញពីគោលការណ៍ដ៏សំខាន់ក្នុងការជំនួសអ្វីមួយ។

តើលោកអ្នកអាចអនុវត្តទៅលើគោលការណ៍នៃការជំនួសនេះក្នុងការ
តយុទ្ធដើម្បីបានភាពបរិសុទ្ធដោយរបៀបណា?

១៧. តើយើងអាចរស់នៅឲ្យមានជីវិតស្អាតបាត ដែលគាប់ព្រះហឫទ័យ
ព្រះជាម្ចាស់បានយ៉ាងដូចម្ដេច?

ទំនុកដំកើង ៥១:១០

សុភាសិត ៤:១៤-១៥

រ៉ូម ១៣:១៤

១ពេត្រុស ១:២២

១៨. ចូរសិក្សាកណ្ឌគម្ពីរ លោកុប្បត្តិ ៣៩:៧-១២ និង ២សាំយូអែល១១:១-៤។ សូមធ្វើការប្រៀបធៀបពីព្រឹត្តិការណ៍រវាង ជីវិតស្តេចដាវីឌ និងលោកយ៉ូសែប។

	លោកយ៉ូសែប	ស្តេចដាវីឌ
តើពួកគាត់បានជួបព្រឹត្តិការណ៍អ្វីខ្លះ?		
តើអ្វីជាអាកប្បកិរិយរបស់ពួកគាត់បន្ទាប់ពីជួបព្រឹត្តិការណ៍នោះ?		
តើពួកគាត់បានទទួលលទ្ធផលអ្វីពីព្រឹត្តិការណ៍នោះ?		

តាមការយល់ឃើញរបស់លោកអ្នកសូមគិតទៅមើលថា ហេតុអ្វីបានជាអ្នកទាំងពីរនេះបានឆ្លើយតបបែបផ្សេងពីគ្នាទៅនឹងស្ថានភាពមួយដែលស្រដៀងគ្នាដូច្នេះ?

ទស្សនៈចំពោះអាពាហ៍ពិពាហ៍

១៩. សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ២:១៨-២៥។

ក) តើនរណាបានចាប់ផ្ដើមធ្វើឲ្យមានអាពាហ៍ពិពាហ៍កើតឡើង?

ខ) តើគោលបំណងនៃអាពាហ៍ពិពាហ៍បង្កើតឡើងដើម្បីអ្វី?

គ) សូមសរសេរខ២៤ឡើងវិញតាមគំនិតរបស់លោកអ្នកផ្ទាល់។

២០. សូមអានកណ្ឌគម្ពីរ ២កូរិនថូស ៦:១៤-១៥។
ក) តើព្រះជាម្ចាស់មានគោលការណ៍បែបណាក្នុងអត្ថបទនេះ?

ខ) តើគោលការណ៍នេះអាចយកទៅអនុវត្តក្នុងអាពាហ៍ពិពាហ៍បាន យ៉ាងដូចម្ដេច?

គ) តើលោកអ្នកគិតថា អ្នកជឿនឹងត្រូវប្រឈមមុខនឹងបញ្ហាអ្វីខ្លះ ប្រសិន បើពួកគេមិនធ្វើតាមគោលការណ៍ខាងលើនេះ?

២១. ក្នុងករណីដែលលោកអ្នកបានរៀបការតាមរបៀបនេះរួចទៅហើយនោះ តើលោកអ្នកគួរធ្វើយ៉ាងដូចម្ដេច? (១កូរិនថូស ៧:១២-១៦)

២២. តើមានហេតុផលសមរម្យណាខ្លះដែលយើងមិនចាំបាច់រៀប
អាពាហ៍ពិពាហ៍នោះ? (១កូរិនថូស ៧:២៧-២៨, ៣២-៣៥)

២៣. សូមអានកណ្ឌគម្ពីរ អេភេសូរ ៥:២១-៣៣ ដែលជាអត្ថបទស្ដីអំពីការ
រៀបអាពាហ៍ពិពាហ៍។

ក) តើព្រះជាម្ចាស់មានបំណងព្រះហឫទ័យយ៉ាងដូចម្ដេចចំពោះប្ដី
គ្រប់ៗរូប ហើយការនេះបានបង្ហាញឲ្យយើងឃើញពីអ្វីខ្លះ?

ខ) តើព្រះជាម្ចាស់មានបំណងព្រះហឫទ័យយ៉ាងដូចម្ដេចចំពោះភរិយា
គ្រប់ៗរូប ហើយការនេះបានបង្ហាញឲ្យយើងឃើញពីអ្វីខ្លះ?

២៤. តើព្រះជាម្ចាស់មានបំណងព្រះហឫទ័យយ៉ាងដូចម្ដេចចំពោះកូនៗរបស់
ទ្រង់ដែលរស់នៅក្នុងលោកីយ៍ដែលពេញដោយភាពពុករលួយ និង
ជំនាន់មួយដែលគ្មានសីលធម៌នោះ? (ភីលីព ២:១៥)

សំណើខគម្ពីរមួយសម្រាប់ សញ្ជឹងគិត និងការទន្ទេញចាំមាត់

១ធីម៉ូថេ ៥:១-២

កុំឲ្យស្ដីបន្ទោសដល់មនុស្សចាស់ៗ ឡើយ ចូរទូន្មានគាត់ទុកដូចជាឪពុកចុះ ហើយមនុស្សដែលក្មេងជាងអ្នក នោះទុកដូចជាប្អូនវិញ ឯស្ត្រីចាស់ៗ ទុកដូចម្ដាយ ហើយពួកស្ត្រីដែលក្មេងជាងអ្នក ទុកដូចជាប្អូនដែរ ដោយសេចក្ដីបរិសុទ្ធសព្វគ្រប់

១ធីម៉ូថេ ៥:១-២

សៀវភៅកំណត់ហេតុរបស់ខ្ញុំ

តើមានចំណុចណាខ្លះនៃជីវិតរបស់លោកអ្នកដែលធ្វើឲ្យលោកអ្នកនៅតែងាយនឹងធ្លាក់ចូលក្នុងអំពើបាបផ្នែកផ្លូវភេទ? តើលោកអ្នកគិតថា ព្រះជាម្ចាស់គង់នៅត្រង់ណាក្នុងការតយុទ្ធដើម្បីឲ្យលោកអ្នកបានបរិសុទ្ធ? តើលោកអ្នកចង់ឲ្យទ្រង់គង់នៅត្រង់ណានៅក្នុងជីវិតរបស់លោកអ្នក?

ចំណុចគួរចងចាំ

សូមសរសេរបន្ថែមមួយឬពីរល្បះដាក់នៅចុងឃ្លាខាងក្រោមនេះដើម្បីសង្ខេប នូវចំណុចសំខាន់ៗដែលលោកអ្នកបានរៀនពីផ្នែកនីមួយៗនៅក្នុងជំពូកនេះ។

ខ្នាតគំរូនៃព្រះជាម្ចាស់

ព្រះជាម្ចាស់មានខ្នាតគំរូដ៏ជាក់លាក់មួយចំពោះភាពបរិសុទ្ធក្នុងការគិត ការនិយាយ និងការប្រព្រឹត្ត។

សារៈសំខាន់នៃភាពបរិសុទ្ធផ្ទាល់ខ្លួន

ព្រះបន្ទូលបានផ្ដល់ហេតុផលយ៉ាងច្បាស់ ដើម្បីឲ្យលោកអ្នករក្សាភាព បរិសុទ្ធផ្ទាល់ខ្លួន។

គន្លងឆ្ពោះទៅរកភាពបរិសុទ្ធ

ព្រះជាម្ចាស់បានប្រទានគោលការណ៍ និងធនធានដើម្បីជួយយើងនៅ ក្នុងការតយុទ្ធដើម្បីឲ្យយើងបានបរិសុទ្ធ។

ទស្សនៈចំពោះអាពាហ៍ពិពាហ៍

ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានបើកសម្ដែងឲ្យយើងឃើញពី ទស្សនវិស័យរបស់ព្រះជាម្ចាស់ចំពោះភាពបរិសុទ្ធក្នុងអាពាហ៍ពិពាហ៍។

ការចូលឲ្យបានស៊ីជម្រៅ

នៅក្នុងវប្បធម៌ភាគច្រើននាពេលបច្ចុប្បន្ននេះ រឿងអាសអាភាសនិងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកំពុងវាយប្រហារទៅលើភាពបរិសុទ្ធរបស់យើង។ ទោះបើអំពើបាបខាងផ្លូវភេទនេះកំពុងតែល្បួងយើងតាមរបៀបទំនើបនាពេលបច្ចុប្បន្ននេះក៏ដោយ ក៏យើងឃើញថា ការតយុទ្ធជាមួយនឹងអំពើបាបផ្នែកភេទគឺមានតាំងពីបុរាណកាលមកម្ល៉េះ។ កណ្ឌគម្ពីរ សុភាសិត (ជាពិសេសនៅជំពូក៥-៧) បានបង្កប់ទៅដោយប្រាជ្ញា ការព្រមាន និងដំបូន្មានអំពីការការពារទៅនឹងភាពបរិសុទ្ធខាងផ្នែកភេទរបស់យើង។ ព្រះបន្ទូលបានព្រមានយើងអំពី លទ្ធផលនិងការគ្រោះថ្នាក់ជាច្រើនទៀតនៃអំពើបាបអសីលធម៌ខាងផ្នែកភេទ។

សូមពិចារណាចេញពីក្នុងជម្រៅចិត្តរបស់លោកអ្នកទៅលើលទ្ធផលអាក្រក់ជាច្រើននៃអំពើបាបអសីលធម៌ខាងផ្លូវភេទ ដោយយោងទៅតាមព្រះបន្ទូលដែលមាននៅក្នុងកណ្ឌគម្ពីរ សុភាសិត ជំពូក៥-៧។

លទ្ធផលអាក្រក់នៃអំពើបាបអសីលធម៌ខាងផ្នែកភេទ

សុភាសិត ៥	សុភាសិត៦:២០-៣៥	សុភាសិត ៧
– ល្វីងដូចជាស្លែង	– ទៅជាមាននំបុ័ងតែ១ ចំណិតប៉ុណ្ណោះ	– បបួលឲ្យព្រមតាម
– មុតដូចជាដាវមានមុខ២	– ដូចជាភ្លើងមកដាក់នៅនាទ្រូង	– បង្ខំឲ្យទៅ
– ឈានទៅជាប់នៅស្ថានឃុំព្រលឹងមនុស្សស្លាប់	– វាត្រូវសង	– ប្រៀបដូចជាគោដែលទៅឯទីសម្លាប់

– តែងតែប្រែប្រួល	– បំផ្លាញជីវិតខ្លួន	– ព្រួញទម្លុះថ្លើម
– បំផ្លាញកិត្តិសព្ទឯង	– លុបសេចក្តីត្មះតិះដៀល	– សត្វស្លាបហើរតម្រង់ទៅជាប់លប់
– ប្រគល់អាយុឯងដល់ពួកសាហាវ	– ទទួលសេចក្តីក្តៅក្រហាយ និងការសងសឹក	– ធ្វើឲ្យរបួសដួល
– ដល់ចុងបំផុត ឯងនឹងត្រូវថ្ងូរ	– ផ្ទុះកំហឹងនិងសងសឹក	– ផ្លូវនាំចុះទៅឯស្ថានឃុំព្រលឹងមនុស្សស្លាប់
– ចាប់យកអ្នកនោះឯង	– មិនមានអ្វីដែលអាចធ្វើឲ្យល្អឡើងវិញបានទេ	
– ត្រូវស្លាប់ទៅ		
– រង្វាន់របស់វាគឺសេចក្តីស្លាប់		

សូមអានជំពូកណាមួយក៏បានក្នុងចំណោមជំពូកទាំងបីដែលដកស្រង់ពីកណ្ឌគម្ពីរ សុភាសិត ដែលបានលើកឡើងនៅតារាងខាងលើនេះ។ តើមានផ្លូវណាខ្លះដែលលោកអ្នកអាចគេចចេញពីការជាប់អន្ទាក់ដោយអំពើបាបអសីលធម៌ខាងផ្លូវភេទបាន ចេញពីជំពូកនោះ? តើមិត្តភក្តិជិតដិតអាចជួយលោកអ្នកបានដោយរបៀបណា? (សាស្តា ៤:៩-១១)

“ *ការរួមភេទបែបស្រើបស្រាលតាមប្រព័ន្ធអ៊ីនធឺណិតគឺគ្រាន់តែជាទម្រង់មួយផ្សេងទៀតនៃការបញ្ជាក់អំពីអារម្មណ៍ផ្នែកភេទដ៏អាត្មានិយមប៉ុណ្ណោះ។ វានឹងធ្វើឲ្យលោកអ្នកតែលតោល និងតែងតែឲ្យលោកអ្នកចង់បង្កើននូវចំណង់តណ្ហាមួយហើយមួយទៀតមិនចេះស្កប់ស្កល់.... ការរួមភេទបែបស្រើបស្រាលតាមប្រព័ន្ធអ៊ីនធឺណិត គឺមានគ្រោះថ្នាក់ណាស់ ពីព្រោះវាតែងតែនាំលោកអ្នកចូលទៅក្នុងទម្រង់នៃការស្រើបស្រាលដ៏អន្តរាយជាច្រើនបែបច្រើនយ៉ាង។ លោកអ្នកអាចនិយាយទៅកាន់ខ្លួនឯងថា “វាមិនអាចទៅរួចទេ វានឹងមិនកើតឡើងចំពោះខ្ញុំឡើយ” ប៉ុន្តែលោកអ្នកគួរអានអ៊ីមែលមួយចំនួនដែលយើងទទួលបានដែលបញ្ជាក់ថា មនុស្សជាច្រើនកាន់តែមានតម្រូវការច្រើនឡើងៗ ហើយពួកគេចាប់ផ្ដើមយល់ថា ពួកគេចូលកាន់តែជ្រៅទៅៗ ស្របពេលដែលពួកគេកំពុងស្វែងរកនូវទម្រង់អាក្រក់ផ្សេងៗទៀតដើម្បីទទួលបានភាពពេញចិត្តពេញថ្លើមខាងផ្លូវភេទរបស់ពួកគេ។*

លោក ក្រេក ហ្គ្រូស និង ម៉ែក ហ្វូស្ទ័រ (Craig Gross and Mike Foster)
ដកស្រង់ចេញពីសៀវភៅ *Questions You Can't Ask Your Mama About Sex*

ជំពូកទី

៤

ភាពស្អាតស្អំ ក្នុងការរស់នៅ

ការរស់នៅក្នុងជីវិតដែលពេញជាមនុស្សស្អាតស្អំអាចជាការមួយដ៏ពិបាក។ ជាធម្មតាយើងមានទំនោរធ្វើជាមនុស្សដែលមានមុខពីរដោយសារ យើងនិយាយរឿងមួយដែលផ្ទុយទៅនឹងរឿងពិតនៃជីវិតរស់នៅរបស់យើង។ ជារៀងរាល់ថ្ងៃ យើងពុះពារក្នុងការជ្រើសរើសការត្រឹមត្រូវ ឬការមិនត្រឹមត្រូវ ហើយការល្អ ឬការអាក្រក់។ ជារឿយៗយើងតែងតែដោះសារពីអំពើបាបរបស់យើង ហើយមិនព្រមធ្វើតាមខ្នាតគំរូនៃភាពស្អាតស្អំរបស់ព្រះជាម្ចាស់ឡើយ។ យើងអាចពន្យល់បកស្រាយពីអំពើបាបរបស់យើងបាន ឬក៏អាចរុញច្រាននូវអំពើបាបទាំងនេះចេញ ហើយលែងទទួលស្គាល់ថាវាជាអំពើបាបទៀត។ ប៉ុន្តែព្រះជាម្ចាស់ជាព្រះដ៏បរិសុទ្ធ ហើយយើងមិនត្រូវអនុញ្ញាតឲ្យមានការសម្របសម្រួលជាមួយអំពើបាបក្នុងជីវិតយើងឡើយ។ ដោយសារទ្រង់គឺជាពន្លឺ នោះទ្រង់នឹងបង្ហាញ

ការពិតចំពោះអ្វីដែលយើងព្យាយាមលាក់បាំងឲ្យយើងឃើញដោយព្រះគុណរបស់ទ្រង់ដើម្បីឲ្យយើងអាចចម្រើនឡើងនូវភាពស្អាតស្អំ។

ការតយុទ្ធដើម្បីភាពស្អាតស្អំ



១. នៅពេលដែលព្រះជាម្ចាស់បានប្រទានក្រិត្យវិន័យទាំងដប់ប្រការ តើទ្រង់មានព្រះបន្ទូលយ៉ាងណាខ្លះទាក់ទងនឹងតម្រូវការរបស់យើង ដើម្បីឲ្យបានភាពស្អាតស្អំ ឬក៏សេចក្តីទៀងត្រង់? (លេវីវិន័យ ១៩:១១)

២. សូមអានពីការតយុទ្ធរបស់សាវ័កប៉ុលដើម្បីភាពស្អាតស្អំនៅក្នុងកណ្ឌគម្ពីរ រ៉ូម ៧:១៥-២០។ តើលោកអ្នកធ្លាប់មានគំនិតដូចសាវ័កប៉ុលក្នុងការតយុទ្ធដើម្បីភាពស្អាតស្អំយ៉ាងដូចម្តេច?

៣. សូមអានរឿងដែលលោកអ្នកបានដឹងរួចមកហើយអំពីការធ្លាក់ចុះរបស់លោកអ័ដាម និងនាងអេវ៉ានៅក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ២:២៥-៣:១៣។ សូមដាក់លេខរៀងតាមដំណើរនៃព្រឹត្តិការណ៍ដែលបានកើតឡើងខាងក្រោមនេះតាមលំដាប់លំដោយៈ

__ ការអាម៉ាស់

__ ការមិនស្តាប់បង្គាប់

__ ការលោក់បំពួន

__ ការបោកបញ្ឆោត

__ ការភ័យខ្លាច

៤. តើយើងអាចចាញ់ការបញ្ឆោតតាមរយៈការណាខ្លះ?

ក) តាមរយៈខ្លួនយើងផ្ទាល់

យ៉ាកុប ១:២២

១យ៉ូហាន ១:៨

ខ) តាមរយៈអ្នកដទៃ

រ៉ូម ១៦:១៧-១៨

អេភេសូរ ៤:១៤

គ) តាមរយៈសាតាំង

លោកុប្បត្តិ ៣:១

២កូរិនថូស ១១:៣-៤

“ *ការអធិស្ឋានដែលឥតពុតមាយាកើតចេញពីភាពស្មោះត្រង់ ដ៏មុតមាំ ភាពចេញផុតពីការលាក់បំពួន ការបោះបង់ចោល នូវការព្យាយាមដែលចង់បានការចាប់អារម្មណ៍ពីអ្នកដទៃ ការទទួលស្គាល់ថាយើងពិតជាមនុស្សមានបាប និងការពឹង ផ្អែកទាំងស្រុងទៅលើព្រះជាម្ចាស់។ ការអធិស្ឋានដែលឥត ពុតមាយា និងចេញពីចិត្តដោយការបន្ទាបខ្លួនគឺជាជម្រើស ដ៏សំខាន់ដែលនាំឲ្យយើងលែងការពារចិត្តខ្លួនឯង លែងធ្វើ ជាមនុស្សមានមុខពីរ។*

ប្រេននែន មែននីង (Brennan Manning)
ដកស្រង់ចេញពីសៀវភៅ *Reflections for Ragamuffins*

៥. ដោយសារយើងងាយនឹងចាញ់បញ្ឆោតនោះ តើយើងអាចដឹងបានថាយើងបានប្រព្រឹត្តអំពើបាប ឬក៏កំពុងតែលាក់បំពួនអំពើបាបរបស់យើងដោយរបៀបណា?

ទំនុកដំកើង ១៩:១២

ទំនុកដំកើង ១៣៩:២៣-២៤

ហេព្រើរ ៤:១២

ការប្រកាសពីកង្វះខាត នៃភាពស្អាតស្អំ

៦. ហេតុអ្វីបានជាមនុស្សមានទំនោរលោភបំពួន ដូច្នេះ? (យ៉ូហាន ៣:១៩-២១)

តើពន្លឺរបស់ព្រះជាម្ចាស់មានតួនាទីជាអ្វី?

៧. យើងត្រូវតែគេចចេញពីសេចក្តីពុតមាយាដោយប្រុងប្រយ័ត្នបំផុត។ ពួកផារិស៊ីនាពេលសម័យព្រះយេស៊ូវគឺជាគំរូដែលបង្ហាញពីរបៀបនៃការមិនមានភាពស្អាតស្អំ។

ក) តើព្រះយេស៊ូវបានបង្ហាញឲ្យឃើញយ៉ាងដូចម្តេចអំពីមនុស្សមានពុត? (ម៉ាកុស ៧:៦-៨)

ខ) សូមសរសេរនូវហេតុផលមួយដែលបញ្ជាក់ថា ការរស់នៅបែបជាមនុស្សមានពុតដែលមិនស្មោះត្រង់ (រ៉ូម ២:២៣-២៤)។

គ) តើសេចក្ដីពុតមាយារបស់មនុស្សដែលកណ្ឌគម្ពីរ ១យ៉ូហាន ៤:២០ លើកឡើងនោះគឺជាអ្វី?

៨. សូមអានកណ្ឌគម្ពីរ កិច្ចការ ៥:១-៥។

ក) តាមការយល់ឃើញរបស់លោកអ្នកសូមគិតទៅមើលថា ហេតុអ្វីបានជាលោកអាណានាសនិយាយកុហក?

ខ) តើគាត់កុហកនរណា ហើយនរណាជាអ្នកដែលបានដាក់គំនាបឲ្យគាត់និយាយកុហក?

គ) តាមការយល់ឃើញរបស់លោកអ្នកសូមគិតទៅមើលថា ហេតុអ្វីបានជាព្រះជាម្ចាស់រាប់ការកុហករបស់លោកអាណានាសជាការខុសឆ្គងយ៉ាងខ្លាំងដូច្នេះ?

៩. តើធ្លាប់មាននរណានិយាយកុហកលោកអ្នកឬទេ? តើលោកអ្នកមានអារម្មណ៍ដូចម្ដេច ហើយការកុហកនោះប៉ះពាល់ដល់ទំនាក់ទំនងរបស់លោកអ្នក និងអ្នកកុហកនោះយ៉ាងដូចម្ដេចខ្លះ?

១០. ជីវិតយើងគួរតែឈរឲ្យមាំមួនទៅនឹងការដែលមនុស្សផ្សេងទៀតល្បួងយើង។ យើងគួររស់នៅប្រកបដោយចិត្តបរិសុទ្ធទៀងត្រង់ មិនមែនធ្វើពើជាអ្នកណាម្នាក់ដែលខុសពីការពិតដើម្បីឲ្យអ្នកដទៃស្រឡាញ់យើងនោះឡើយ។ សូមនឹកស្រមៃថាមានម៉ាស៊ីនមួយដែលអាចទាញយកគំនិត និងចរិតលក្ខណៈរបស់នរណាម្នាក់មកដាក់នៅលើផ្ទាំងបញ្ចាំងកុនដើម្បីបង្ហាញឲ្យអ្នកដទៃឃើញ។

ក) តើលោកអ្នកចង់ឲ្យគេប្រើម៉ាស៊ីននេះមកលើរូបលោកអ្នកដែរឬទេ?

ខ) ហេតុអ្វីចង់ ឬហេតុអ្វីមិនចង់?

១១. សូមពិចារណាទៅលើរបៀបសាមញ្ញៗមួយចំនួនខាងក្រោមនេះដែលវាអាចធ្វើឲ្យភាពស្អាតស្អំរបស់យើងខូច។ តើចំណុចមួយណាដែលជាបញ្ហារបស់លោកអ្នក បើមានសូមគូសសញ្ញាគ្រីស (✓)?

__ ការរស់នៅដោយមានមុខពីរ

__ ការនិយាយកុហកកំប៉ិកកំប៉ុក

__ និយាយបាត់ដៃខ្នងដៃ

__ ការបោកបញ្ឆោត

__ ពូកែខាងទាក់ទាញអារម្មណ៍មនុស្សផ្សេងទៀតឲ្យមានចំណាប់ អារម្មណ៍លើខ្លួនភ្លាមៗ

__ មិនគោរពពាក្យសន្យា

__ ការលាក់បាំងដើម្បីការពារខ្លួន

__ ការថតចម្លង ឬក៏ការទាញយកកម្មវិធីអ្វីមួយដែលខុសច្បាប់

__ (ផ្សេងៗ)________________________________

“ *ក្នុងនាមខ្លួនខ្ញុំជាមនុស្សដែលស្អាតស្អំម្នាក់ ខ្ញុំឈប់កំណត់ខ្លួនខ្ញុំដោយអំពើបាបរបស់ខ្ញុំ ឬក៏អំពើបាបដែលទាស់នឹងខ្ញុំទៀតហើយ ប៉ុន្តែខ្ញុំកំណត់ខ្លួនខ្ញុំតាមអ្វីដែលព្រះជាម្ចាស់បានប្រកាសថា ខ្ញុំជាអ្នកណាវិញ។*

ប៊ៀល ស្រ្តល (Bill Thrall)
អ្នកដឹកនាំក្នុងអង្គការ Leadership Catalyst, Inc.

ការអនុវត្តនូវសេចក្តីទៀងត្រង់

១២. សូមអានកណ្ឌគម្ពីរ ១ថែស្សាឡូនីច ២:៤-១០ ដោយសារតែសាវ័កប៉ុលជាមនុស្សស្អាតស្អំនោះ តើមានការអ្វីខ្លះដែលគាត់មិនអាចធ្វើបានទាក់ទងនឹងទំនាក់ទំនងរបស់គាត់ជាមួយក្រុមជំនុំនៅក្រុងថែស្សាឡូនីច?

១៣. សូមសញ្ជឹងគិតលើកណ្ឌគម្ពីរ កិច្ចការ ២៤:១៦ និង ២កូរិនថូស ៨:២១។ តើមានការអនុវត្តណាខ្លះដែលអាចឲ្យលោកអ្នករក្សាបញ្ញាចិត្តដ៏បរិសុទ្ធនៅចំពោះព្រះជាម្ចាស់ និងមនុស្សដទៃទៀតបាន?

១៤. សេចក្ដីទៀងត្រង់គួរតែបានដាក់បង្ហាញនៅក្នុងគ្រប់ទាំងទិដ្ឋភាពនៃជីវិតរបស់យើង។ សូមសរសេរចុះនូវចំណុចមួយចំនួនដែលទាក់ទងនឹងសេចក្ដីទៀងត្រង់ដែលយើងអាចធ្វេសប្រហែសនឹងប្រព្រឹត្តតាម។

រ៉ូម ១៣:៦-៧

កូល៉ុស ៣:២៣-២៥

១ពេត្រុស ២:១៣-១៤

សូមពិចារណាទៅលើខ្នាតគំរូសំខាន់ៗទាំងពីរខាងក្រោមនេះដែលទាក់ទងនឹងសេចក្ដីទៀងត្រង់៖

- សូមប្រាកដខ្លួនឯងថា អ្វីៗដែលលោកអ្នកមាននោះគឺបានទទួលដោយទៀងត្រង់។
- នៅពេលដែលលោកអ្នកនិយាយ សូមនិយាយនូវសេចក្ដីពិត។ មិនត្រូវឲ្យមានការកុហកនោះឡើយ ទោះបីជាការកុហកនោះតិចតួចក៏ដោយ។

ភាពទៀងត្រង់ក្នុងការនិយាយស្ដី

១៥. តើការនិយាយស្ដីរបស់លោកអ្នកបង្ហាញប្រាប់ពីអ្វី? (ម៉ាថាយ ១២:៣៤-៣៥)

តាមការយល់ឃើញរបស់លោកអ្នកសូមគិតទៅមើលថា ហេតុអ្វីបានជាមនុស្សគ្រប់បាំងសេចក្ដីពិតអំពីខ្លួនគេម្នាក់ៗ?

១៦. សូមអានកណ្ឌគម្ពីរ យ៉ាកុប ៣:៨-១០។ តើពាក្យសម្ដីរបស់យើងមានអំណាចយ៉ាងដូចម្ដេច?

តើការនេះបង្ហាញឲ្យឃើញពីការតយុទ្ធរបស់យើងដើម្បីភាពស្អាតស្អំ យ៉ាងដូចម្ដេច?

១៧. យើងកសាងការទុកចិត្តនៅក្នុង ទំនាក់ទំនងតាមរយៈភាពស្អាតស្អំរបស់ យើង ហើយទម្លុះការទុកចិត្តតាមរយៈ ភាពមិនស្មោះត្រង់របស់យើង។ សូម ពិចារណាទៅលើកណ្ឌគម្ពីរ សុភាសិត ២៦:២៨។ តើការនិយាយកុហកនាំឲ្យមានការបាត់បង់នូវទំនុកចិត្តបាន យ៉ាងដូចម្ដេច? តើលោកអ្នកមានអារម្មណ៍ដូចម្ដេច បន្ទាប់ពីមាននរណា ម្នាក់និយាយកុហកលោកអ្នកនោះ?

ក) តើការនិយាយកុហកបានធ្វើឲ្យសេចក្ដីទុកចិត្តរបស់លោកអ្នកចំពោះ នរណាម្នាក់ផ្សេងទៀតចុះថយយ៉ាងដូចម្ដេច?

ខ) សូមគិតអំពីពេលមួយដែលលោកអ្នកមិនបាននិយាយការពិតទៅកាន់នរណាម្នាក់។ នៅពេលដែលលោកអ្នកនិយាយកុហកដូចគ្រានោះ តើលោកអ្នកអាចធ្វើអ្វីបានខ្លះ ដើម្បីអាចចូលទៅក្នុងពន្លឺរនៃសេចក្តីពិតរបស់ព្រះជាម្ចាស់?

១៨. គ្រប់ទាំងការមួលបង្កាច់ពីសេចក្តីពិត មិនថាជាពាក្យសម្តី ការនិយាយបំផ្លើស សកម្មភាព អត្តចរិត ឬក៏ការធ្វើមិនដឹងមិនឮយ៉ាងណានោះទេ គឺសុទ្ធតែជាការបោកបញ្ឆោត និងការកុហកទាំងអស់។ ហេតុអ្វីបានជាការនិយាយកុហក និងការប្រទេចផ្តាសាមិនស័ក្តិសមនៅក្នុងជីវិតនៃអ្នកដើរតាមព្រះយេស៊ូវ? (កូល៉ុស ៣:៨-១០)

១៩. សូមសម្រាយបទគម្ពីរខាងក្រោមនេះឡើងវិញតាមគំនិតរបស់លោកអ្នក៖

អេភេសូរ ៤:២៩

កូល៉ុស ៤:៦

២០. តើលោកអ្នកអាចអនុវត្តខគម្ពីរ ណាមួយក្នុងសំណួរទី១៩ ស្ដីពីទំនាក់ទំនងរបស់លោកអ្នកជាមួយនរណាម្នាក់ដែលលោកអ្នកស្គាល់បានដែរឬទេ? តើលោកអ្នកនឹងធ្វើដូចម្ដេច ហើយនៅពេលណា?

> *តម្លាភាពមានន័យយ៉ាងសាមញ្ញថា ជាការបើកសម្ដែងពីខ្លួនឯងផ្ទាល់ដល់អ្នកដទៃផ្សេងទៀត។ ....គឺជាការជ្រើសរើសដោយចេតនាក្នុងការបើកចិត្តឲ្យអ្នកដទៃដាក់ឥទ្ធិពលរបស់គេមកលើខ្លួនលោកអ្នក។ ....គឺជាការអនុញ្ញាតឲ្យគេស្គាល់ពីការឈឺចាប់ដែលមាននៅក្នុងសេចក្ដីកម្សោយរបស់លោកអ្នក ហើយអនុញ្ញាតឲ្យគេមកថែរក្សាលោកអ្នក មិនត្រឹមតែប៉ុណោះវាក៏ជាការជ្រើសរើសដើម្បីឲ្យអ្នកដទៃស្គាល់លោកអ្នក ហើយអនុញ្ញាតឲ្យគេមានឥទ្ធិពលមកលើលោកអ្នកផងដែរ។*

បៀល ស្រ្តល, ខេន ម៉ែកអិលរ៉ាស និងប្រ៊ូស ម៉ែកនីខូល (Bill Thrall, Ken McElrath, and Bruce McNicol)
ដកស្រង់ចេញពីសៀវភៅ *Beyond Your Best*

២១. សូមអានកណ្ឌគម្ពីរ យ៉ាកុប ៥:១៦ ហើយសូមពិចារណាទៅលើសម្រង់សម្ដីដែលដកស្រង់ចេញពីសៀវភៅ *Beyond Your Best* នៅខាងលើនេះ។

ក) តើលោកអ្នកគិតថា ការបើកសម្ដែងពីខ្លួនឯងក្នុងទំនាក់ទំនងដ៏ស្និទ្ធស្នាលរបស់លោកអ្នកដោយការបង្ហាញចេញយ៉ាងស្មោះត្រង់ពីខ្លួនលោកអ្នកផ្ទាល់មានលក្ខណៈយ៉ាងដូចម្ដេច?

ខ) សូមពណ៌នាអំពីពេលវេលាមួយដែលលោកអ្នកបានបើកចិត្ត បង្ហាញឲ្យអ្នកដទៃឃើញពីចំណុចណាមួយនៃសេចក្តីកម្សោយរបស់ លោកអ្នក។

គ) នៅពេលដែលលោកអ្នកបានបន្ទាបខ្លួនឲ្យស្ថិតនៅក្រោមឥទ្ធិពល របស់នរណាម្នាក់នោះ តើលោកអ្នកបានទទួលលទ្ធផលយ៉ាង ដូចម្តេច?

សំណើខគម្ពីរមួយសម្រាប់ សញ្ជឹងគិត និងការទន្ទេញចាំមាត់

អេភេសូរ ៤:២៩

មិនត្រូវឲ្យមានពាក្យអាក្រក់ណាមួយ ចេញពីមាត់អ្នករាល់គ្នាឡើយ ចូរបញ្ចេញតែពាក្យណាដែលល្អៗ សំរាប់នឹងស្អាងចិត្តតាមត្រូវការ ដើម្បីឲ្យបានផ្តល់ព្រះគុណដល់អស់អ្នកដែលស្តាប់

អេភេសូរ ៤:២៩

សៀវភៅកំណត់ហេតុរបស់ខ្ញុំ

ដំណើរឆ្ពោះទៅកាន់ភាពស្អាតស្អំ តម្រូវឲ្យយើងចូលមកកាន់ពន្លឺ ហើយពន្លឺនោះតម្រូវមាន ការរស់នៅក្នុងសេចក្ដីពិត និងការនិយាយតែសេចក្ដីពិត។ តាមរយៈការសិក្សានេះ តើព្រះជាម្ចាស់បានបង្ហាញអ្វីខ្លះដល់លោកអ្នកស្ដីអំពីតម្រូវការរបស់លោកអ្នកដើម្បីទទួលបាននូវការរីកចម្រើនក្នុងភាពស្អាតស្អំ? តើលោកអ្នកដាក់សេចក្ដីទុកចិត្តដល់អ្នកណាក្នុងដំណើរដ៏វែងឆ្ងាយនេះ?

> *ការចង់ធ្វើជាមនុស្សដែលគាប់ព្រះហឫទ័យព្រះមិនមែនមានន័យថា យើងត្រូវធ្វើជាមនុស្សដែលគ្រប់លក្ខណ៍នោះទេ ប៉ុន្តែយើងត្រូវព្យាយាមធ្វើជាមនុស្សដែលស្អាតស្អំ និងស្មោះត្រង់នឹងការពិត។*
>
> បៀល ស្រ្តុល (Bill Thrall)
> អ្នកដឹកនាំក្នុងអង្គការ Leadership Catalyst, Inc.

ចំណុចគួរចងចាំ

សូមសរសេរបន្ថែមមួយឬពីរល្បះ ដាក់នៅចុងឃ្លាខាងក្រោមនេះដើម្បីសង្ខេប នូវចំណុចសំខាន់ៗដែលលោកអ្នកបានរៀនពីផ្នែកនីមួយៗនៅក្នុងជំពូកនេះ។

ការតយុទ្ធដើម្បីភាពស្អាតស្អំ

ការបោកបញ្ឆោតនាំឲ្យយើងមានការតយុទ្ធ ហើយវាបង្ហាញថាយើងត្រូវការភាពស្អាតស្អំ។

ការប្រកាសពីកង្វះខាតនៃភាពស្អាតស្អំ

គោលបំណងរបស់យើងមិនមែនចង់បានជីវិតដែលគ្មានបាបល្អឥតខ្ចោះនោះឡើយ ប៉ុន្តែគឺជាការចង់បាននូវជីវិតដែលមិនមានការលាក់បំពួន។

ការអនុវត្តនូវសេចក្ដីទៀងត្រង់

ព្រះជាម្ចាស់បានត្រាស់ហៅយើងឲ្យខិតខំស្វែងរកបញ្ញាចិត្តឥតសៅហ្មងមួយចំពោះទ្រង់ និងអ្នកដទៃ។

ភាពទៀងត្រង់ក្នុងការនិយាយស្ដី

ពាក្យសម្ដីរបស់យើងសម្ដែងនិងបង្ហាញឲ្យឃើញពីក្រអៅដួងចិត្តរបស់យើង។

ការចូលឲ្យបានស៊ីជម្រៅ

ការស្មោះត្រង់ចំពោះខ្លួនឯងគឺជារឿងមួយដ៏ពិបាក។ សូមអានកណ្ឌគម្ពីរទំនុកដំកើង ៥១:៦។ តើលោកអ្នកនឹងពណ៌នាយ៉ាងដូចម្ដេចពីសេចក្ដីពិតចំពោះលោកអ្នកផ្ទាល់ទាក់ទងនឹងមនោសញ្ចេតនា អាកប្បកិរិយា អត្តសញ្ញាណទំនាក់ទំនង និង ចរិតលក្ខណៈ។ល។ តើមនុស្សដែលមានភាពចាស់ទុំម្នាក់ដែលកំពុងមានទំនាក់ទំនងជាមួយលោកអ្នក គាត់និយាយពីសេចក្ដីពិតមកកាន់ជីវិតលោកអ្នកយ៉ាងដូចម្ដេចខ្លះ?

ហេតុអ្វីបានជាដំណើរការនេះមានភាពលំបាកយ៉ាងដូច្នេះ? តើលោកអ្នកមានអារម្មណ៍ថា លោកអ្នកមានភាពស្មោះត្រង់ដល់កម្រិតណានៅថ្ងៃនេះ?

ជំពូកទី

៥

ការអភិវឌ្ឍផ្នែកអត្តចរិត ក្នុងការរងទុក្ខ

ប្រសិនបើអត្តចរិតរបស់យើងដូចជាមាស យើងមិនត្រឹមតែជីកកកាយយ៉ាងជ្រៅដើម្បីស្វែងរកវាប៉ុណ្ណោះទេ ប៉ុន្តែយើងថែមទាំងយកវាមកស្លបន្សុទ្ធជាច្រើនលើកច្រើនសារទៀតផង។ ព្រះជាម្ចាស់បានប្រើវិធីខុសៗគ្នាជាច្រើនក្នុងការធ្វើឲ្យយើងមានចរិតចាស់ទុំតាមរយៈការចម្រាញ់ ឬក៏បន្សុទ្ធនូវអត្តចរិតរបស់យើង។ ប៉ុន្តែក៏មានសំណួរដែលមិនមានដំណោះស្រាយជាច្រើនដែលធ្វើឲ្យយើងមានការរីកចម្រើនដូចជា៖ «តើសេចក្ដីល្អរបស់ព្រះជាម្ចាស់ស្ថិតនៅត្រង់ណានៅពេលដែលមនុស្សលោកជួបសេចក្ដីវេទនា? ហេតុអ្វីបានជាព្រះជាម្ចាស់មិនព្រមបញ្ឈប់នូវភាពឈឺចាប់ ជាពិសេសនៅពេលដែលវាមើលទៅមិនសមនឹងកើតមានសោះនោះ?»

អ្នកជឿលើព្រះយេស៊ូវគឺនៅតែមានការរងទុក្ខ និងការឈឺចាប់។ មនុស្សគ្រប់គ្នាសុទ្ធតែធ្លាប់ឆ្លងកាត់នូវការឈឺថ្កាត់ ទុក្ខព្រួយ សេចក្ដីស្លាប់ ការខកចិត្ត និងការឈឺចាប់។ នៅពេលដែលយើងជាអ្នកជឿខំអត់ទ្រាំជាមួយនឹងការឈឺចាប់ ការរងទុក្ខ នោះយើងនឹងអាចទទួលបាននូវការកំសាន្តចិត្ត និងកម្លាំងពីព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ដែលថា ទ្រង់ដែលមានសិទ្ធិអំណាចដ៏ធំកំពុងតែធ្វើតាមបំណងព្រះហឫទ័យទ្រង់ក្នុងការសង្គ្រោះយើងម្នាក់ៗ ហើយយើងអាចសង្ឃឹមលើជីវិតអស់កល្បជានិច្ចដ៏រុងរឿង។

ការគ្រប់គ្រងដ៏ធំបំផុតរបស់ព្រះជាម្ចាស់

១. តើខគម្ពីរទាំងប៉ុន្មានខាងក្រោមនេះបង្រៀនយើងអំពីទស្សនវិស័យ និងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់យ៉ាងដូចម្ដេចខ្លះ?

អេសាយ ៤៥:៥-៧

អេសាយ ៤៦:៩-១១

តើសេចក្តីពិតទាំងឡាយអំពីអធិបតេយ្យភាព*របស់ព្រះជាម្ចាស់ជួយកំសាន្តចិត្តលោកអ្នក ឬក៏រំខានចិត្តលោកអ្នក? សូមពន្យល់៖

២. តើលោកយ៉ូសែបបានមានប្រសាសន៍យ៉ាងដូចម្តេច អំពីកាលៈទេសៈដ៏លំបាកទាំងឡាយ និងអ្នកបង្កបញ្ហាជាច្រើនដែលគាត់បានប្រឈមមុខនោះ? (លោកុប្បត្តិ ៥០:២០)

* **អធិបតេយ្យភាពរបស់ព្រះជាម្ចាស់** មានន័យថា ព្រះជាម្ចាស់គ្រប់គ្រង់លើអ្វីៗទាំងអស់។

៣. សូមអានកណ្ឌគម្ពីរ រ៉ូម ៨:១៨ និង៨:២៨។

ក) តើសាវ័កប៉ុលមានអាកប្បកិរិយា និងសេចក្ដីសន្និដ្ឋានយ៉ាងណា?

ខ) តើគំនិតទាំងនេះអាចជួយលោកអ្នកដោះស្រាយជាមួយនឹងកាលៈទេសៈដែលលោកអ្នកប្រឈមមុខនោះយ៉ាងដូចម្ដេច?

៤. សូមពណ៌នាពីពេលវេលាណាមួយដែលលោកអ្នកបានធ្វើហើយមើលទៅហាក់បីដូចជាមិនបានបង្កើតផលផ្លែអ្វីទាល់តែសោះ តែក្រោយមកវាបែរជាបានបង្កើតផលផ្លែទៅវិញ។

៥. សូមអានកណ្ឌគម្ពីរ អេសាយ ៥២:១៣-៥៣:១២។

គោលបំណងក្នុងការរងទុក្ខ

ក) តើព្រះគ្រីស្ទបានរងទុក្ខលំបាកដោយអយុត្តិធម៌របៀបណាខ្លះ?

ខ) តើទ្រង់ឆ្លើយតបទៅនឹងការរងទុក្ខលំបាកនោះយ៉ាងដូចម្ដេច? (៥៣:៧)

គ) តើទ្រង់ទ្រាំទ្រនឹងទុក្ខលំបាកនោះសម្រាប់ជាប្រយោជន៍ដល់នរណាទៅ? (៥៣:៨, ១១-១២)

៦. សូមបន្ថែមចម្លើយរបស់លោកអ្នកដោយផ្ទាល់ទៅកាន់សំណួរទាំងបីខាងលើនេះដោយប្រើកណ្ឌគម្ពីរ ១ពេត្រុស ២:២១-២៤។

តើការរងទុក្ខរបស់ព្រះគ្រីស្ទមានការប៉ះពាល់ចិត្តដល់លោកអ្នក

យ៉ាងដូចម្ដេច? (ខ២១)

៧. តើមានហេតុផលណាខ្លះដែលព្រះជាម្ចាស់សាកល្បងកូនចៅរបស់អ៊ីស្រាអែល?

ចោទិយកថា ៨:២-៣

ចោទិយកថា ៨:១៦

> *ព្រះជាម្ចាស់កំពុងតែចែចង់យើង។ វាគឺជាការថើបដ៏ចម្លែកមួយរបស់ព្រះជាម្ចាស់ដែលផ្ទុយពីការថើបរបស់យូដាអ៊ីស្ការីយ៉ុត ហើយការថើបនេះគឺដើម្បីស្គាល់យើងឡើង មិនមែនក្បត់នឹងយើងនោះទេ។ ភាពឈឺចាប់ប្រៀបដូចជាផ្លូវតូចមួយដែលនាំយើងចូលទៅក្នុងសេចក្ដីស្រឡាញ់ដ៏ស្និទ្ធស្នាលបំផុតជាមួយអ្នកបម្រើ (ព្រះយេស៊ូវ) ដែលកំពុងរងទុក្ខលំបាក។*
>
> ម៉ាក ប៊ុឆនែន (Mark Buchanan)
> ដកស្រង់ចេញពីសៀវភៅ *Your God Is Too Safe*

៨. តើមានរបៀបណាផ្សេងទៀតដែលព្រះជាម្ចាស់នាំការល្អចេញមកពីការ

រងទុក្ខលំបាកនោះ?
យ៉ូហាន ១៥:២

ហេព្រើរ ១២:៦-៧, ១០

១ពេត្រុស ១:៦-៧

តើលោកអ្នកអាចនឹងពណ៌នាអំពីបំណង ព្រះហឫទ័យដ៏ល្អរបស់ព្រះជាម្ចាស់ក្នុង ការអភិវឌ្ឍ និងការការពារយើងបានយ៉ាង ដូចម្ដេចខ្លះ?

សេចក្ដីទុក្ខសោកគឺជាការល្អ។ វាគឺជាផ្នែកមួយដែលលាងជម្រះ

“ *ចិត្តរបស់យើង។ វាបំផ្លាញខ្សែជីវិតខ្ញុំ ហើយនេះគឺជាផ្នែកដ៏ល្អបំផុតនៃសេចក្តីទុក្ខសោក។ ខ្ញុំត្រូវការជីវិតដែលវេទនា។ គ្មានការការពារខ្លួនណាទៀតឡើយ។ យើងត្រូវតែយំសោកដោយសារវាគឺជាវិធីតែមួយគត់ដែលចិត្តរបស់យើងអាចនៅមានសេរីភាព និងរស់នៅក្នុងលោកីយ៍នេះបាន។ ហេតុអ្វីបានជាដូច្នេះ? ដោយសារតែសេចក្តីទុក្ខលំបាកនាំឲ្យយើងឈប់ពីការខិតខំប្រឹងប្រែងយ៉ាងខ្នះខ្នែងជាជាងការណាផ្សេងៗទៀត។ ការយំសោកគឺជាថ្នាំបន្សាបចំពោះការទាមទារជាកម្មសិទ្ធិមិនចេះចប់មិនចេះហើយនោះឯង។*

ចន អែលឌ្រិដច៍ (John Eldredge)
ដកស្រង់ចេញពីសៀវភៅ *The Jouney of Desire*

៩. សូមសញ្ជឹងគិតលើព្រះបន្ទូលព្រះយេស៊ូវនៅក្នុងកណ្ឌគម្ពីរ យ៉ូហាន ១៥:១៨-២១។

ក) តើការនេះបើកបង្ហាញឲ្យយើងឃើញអំពីអាកប្បកិរិយារបស់លោកីយ៍ចំពោះព្រះជាម្ចាស់យ៉ាងដូចម្តេចខ្លះ?

ខ) ហេតុអ្វីបានជាយើងអាចរំពឹងលើការឆ្លើយតបបែបនេះបាន?

គ)តើលោកអ្នកមានអារម្មណ៍យ៉ាងដូចម្តេចចំពោះភាពជាក់ស្តែងនេះ?

ការឆ្លើយតបរបស់លោកអ្នកចំពោះការរងទុក្ខ

១០. សូមអានកណ្ឌគម្ពីរ លូកា ៦:២២-២៣
និង១ពេត្រុស ៤:១២-១៣។

ក)តើការរងទុក្ខប្រភេទណាដែលយើងអាចរំពឹងទុកបាន?

ខ)តើការនេះនឹងជះឥទ្ធិពលមកលើយើងយ៉ាងដូចម្តេច ទាំងពេលបច្ចុប្បន្ន និងអនាគត?

១១. សូមពិនិត្យមើលនៅក្នុងកណ្ឌគម្ពីរ យ៉ាកុប ១:២-៤។

ក) តើយើងអាចទទួលបាននូវការអភិវឌ្ឍ និងមានភាពចាស់ទុំខាងឯវិញ្ញាណតាមរយៈ ការលំបាកផ្សេងៗដែលយើងជួបប្រទះបានយ៉ាងដូចម្តេច?

ខ) ហេតុអ្វីបានជាការប្រឈមមុខនឹងសេចក្តីល្បួងដោយសេចក្តីអំណរមានការលំបាកយ៉ាងដូច្នេះ?

គ) ហេតុអ្វីបានជាយើងអាចមានទំនុកចិត្ត និងភាពជឿជាក់នៅក្នុងដំណើរនេះ?

១២. សូមពិចារណាទៅលើកណ្ឌគម្ពីរ យ៉ូហាន ១៦:៣៣ និង ១ពេត្រុស ៤:១៩។ ចំណុចសំខាន់នៃការទ្រាំទ្រនឹងការរងទុក្ខលំបាក នោះគឺទំនុកចិត្ត និងភាពជឿជាក់លើព្រះជាម្ចាស់។ តើយើងមានទំនុកចិត្តបែបណា?

១៣. សូមអានកណ្ឌគម្ពីរ អេភេសូរ ៥:២០ និង ១ថែស្សាឡូនីច ៥:១៨។

ក) តើព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យយើងឆ្លើយតបចំពោះស្ថានភាពទាំងឡាយយ៉ាងដូចម្ដេចខ្លះ?

ខ) ហេតុអ្វីបានជាការឆ្លើយតបនេះមានសារៈសំខាន់?

គ) ជារឿយៗការឆ្លើយតបរបស់យើងចំពោះការរងទុក្ខលំបាក រួមមាន ការខឹងសម្បារ សេចក្ដីភ័យខ្លាច ភាពអាម៉ាស់ និងលក្ខណៈនៃអារម្មណ៍ផ្សេងៗទៀត។ តើលោកអ្នកអាចមានអារម្មណ៍ដ៏ពិត ហើយទាំងអរព្រះគុណព្រះជាម្ចាស់ចំពោះទុក្ខលំបាកទាំងអស់នោះបានដោយរបៀបណា?

១៤. សូមអានកណ្ឌគម្ពីរ ភីលីព ១:១២-២១។

ក) តើសាវ័កប៉ុលបានរងទុក្ខលំបាកយ៉ាង ណាខ្លះ?

ខ) តើគាត់មានអាកប្បកិរិយាយ៉ាងដូចម្ដេច?

គ) តើការរងទុក្ខលំបាករបស់គាត់មានលទ្ធផលយ៉ាងដូចម្ដេចខ្លះ?

១៥. តើមនុស្សដែលបានរៀបរាប់ខាងក្រោមនេះ មានអាកប្បកិរិយាបែបណា ចំពោះការរងទុក្ខរបស់ពួកគេនោះ?

ពួកសាវ័ក៖ កិច្ចការ ៥:៤០-៤១

លោកស្ទេផាន៖ កិច្ចការ ៧:៥៩-៦០

លោកយ៉ូប៖ យ៉ូប ១:២០-២២(សូមមើលបន្ថែម យ៉ូប ១:៦-១៩)

១៦. ពេលដែលលោកអ្នករងទុក្ខលំបាក តើលោកអ្នកធ្លាប់បានចោទសួរព្រះជាម្ចាស់ដូចជាលោកយ៉ូបដែរឬទេ? (យ៉ូប ៣:១១, ២០) តើលោកអ្នកធ្លាប់ឆ្ងល់លើ . . .

__ការល្អរបស់ទ្រង់

__សេចក្តីស្រឡាញ់របស់ទ្រង់

__អំណាចរបស់ទ្រង់

__ប្រាជ្ញារបស់ទ្រង់

__ភាពពេញចិត្តរបស់ទ្រង់លើរូបលោកអ្នក

ការផ្អាកបន្តិចដើម្បីអធិស្ឋាន

សូមប្រាប់ព្រះជាម្ចាស់ថា លោកអ្នកបានចូលរួមតយុទ្ធជាមួយនឹងទ្រង់ ហើយសូមឲ្យទ្រង់ជួយណែនាំផ្លូវលោកអ្នកចូលទៅកាន់សេចក្ដីស្រឡាញ់ដែលចេញពីព្រះហឫទ័យប្រចណ្ឌចំពោះលោកអ្នក។

ចម្លើយតបរបស់យើងចំពោះបញ្ហាទាំងឡាយបង្ហាញឲ្យឃើញពីកម្រិតនៃភាពចាស់ទុំខាងឯព្រលឹងវិញ្ញាណរបស់យើង។ ហើយបញ្ហានីមួយៗគឺជាឱកាសមួយដើម្បីអភិវឌ្ឍការរីកចម្រើនផ្នែកអត្តចរិត។

១៧. តើលោកអ្នកគិតថា មានវិធីវិជ្ជមាន និងអវិជ្ជមានណាខ្លះដែលយើងអាចឆ្លើយតបនៅពេលដែលយើងកំពុងស្ថិតនៅក្នុងស្ថានភាពនៃការរងទុក្ខ?

ចម្លើយតបបែបវិជ្ជមាន

ចម្លើយតបបែបអវិជ្ជមាន

តើចម្លើយតបបែបអវិជ្ជមានរបស់យើងបង្ហាញពីអ្វី?

១៨. សូមមើលនៅក្នុងអត្ថបទដែលមាននៅក្នុងកណ្ឌគម្ពីរខាងក្រោមនេះ ហើយពិនិត្យមើលថា តើវាអាចបន្ថែមអត្ថន័យអ្វីខ្លះទៅក្នុងចម្លើយខាងលើរបស់លោកអ្នក។

រ៉ូម ១២:១៧-២១

ហេព្រើរ ១២:១៤-១៥

ការលូតលាស់តាមរយៈការរងទុក្ខ

១៩. សូមអានកណ្ឌគម្ពីរ រ៉ូម ៥:៣-៥។ តើការរងទុក្ខអាចជួយអភិវឌ្ឍយើងបានយ៉ាងដូចម្ដេច?

២០. តើការដែលព្រះជាម្ចាស់វាយផ្ចាលលោកអ្នកពេញដោយសេចក្ដីស្រឡាញ់ នឹងបង្កើតឲ្យមានផលប្រយោជន៍អ្វីខ្លះ? (ហេព្រើរ ១២:១០-១១)

២១. សូមអានកណ្ឌគម្ពីរ ២កូរិនថូស ១:៣-៤។

ក) តើអត្ថបទនេះប្រាប់លោកអ្នកអំពីគុណប្រយោជន៍នៃការរងទុក្ខយ៉ាងណាខ្លះ?

ខ) សូមប្រាប់ឈ្មោះនរណាម្នាក់ដែលលោកអ្នកស្គាល់ ដោយដឹងថា អ្នកនោះកំពុងតែស្ថិតនៅក្នុងពេលវេលានៃការរងទុក្ខ។

គ) តើលោកអ្នកអាចលើកទឹកចិត្តដល់បុគ្គលរូបនេះដោយរបៀបណាខ្លះ?

“ *ក្រៅពីវត្តមានរបស់ព្រះជាម្ចាស់ គ្មានការប្រោសឲ្យជាណាមួយសម្រាប់សេចក្តីទុក្ខសោករបស់យើងនោះទេ។ ពេលវេលាគ្រាន់តែអាចជួយឲ្យយើងបានធូរស្បើយបន្តិចតែប៉ុណ្ណោះ។ ឯដំណឹងល្អ នៅពេលដែលដួងចិត្តរបស់យើងត្រូវខ្ទេចខ្ទាំនោះ គឺព្រះជាម្ចាស់នឹងអញ្ជើញយើងឲ្យយំសោកដោយសេរីក្នុងវត្តមានដ៏ធំដែលពេញដោយសេចក្តីស្រឡាញ់របស់ទ្រង់។ ភាពឈឺចាប់របស់យើងមិនអាចគំរាមកំហែងទ្រង់បានឡើយ ហើយវាក៏មិនអាចបណ្តាលឲ្យទ្រង់មានការភ័យខ្លាច ថាយើងនឹងបំផ្លាញព្រះកិត្តិនាមទ្រង់នោះឡើយ។ ទ្រង់មិនបានដកថយពីយើងពេលដែលយើងគិតថាខ្លួនយើងមិនបរិសុទ្ធ សូម្បីតែនៅពេលដែលយើងឈឺចាប់រហូតដល់យើងទ្រាំមិនបានក្តី ក៏យើងនៅតែជាអ្នកសំណព្វរបស់ទ្រង់ជារៀងរហូត។*

សាលី ប្រ៊ីដលើហ្វ (Sadlly Breedlove)
ដកស្រង់ចេញពីសៀវភៅ *Choosing Rest*

២២. សូមសញ្ជឹងគិតលើកណ្ឌគម្ពីរ ទំនុកដំកើង ១១៩:៥០, ៧១, ៧៦ និងសម្រង់សម្តីរបស់លោក សាលី ប្រ៊ីដលើហ្វ នៅទំព័រមុន។ តើការរងទុក្ខលំបាកបានជះឥទ្ធិពលដល់សេចក្តីស្រឡាញ់របស់លោកអ្នកជាមួយនឹងព្រះជាម្ចាស់យ៉ាងដូចម្តេចខ្លះ? តើអ្នកនិពន្ធកណ្ឌគម្ពីរ ទំនុកដំកើង ក្នុងជំពូក ១១៩ នេះបានឆ្លើយតបទៅនឹងការរងទុក្ខយ៉ាងដូចម្តេចខ្លះ?

សំណើខគម្ពីរមួយសម្រាប់ សញ្ជឹងគិត និងការទន្ទេញចាំមាត់

១ពេត្រុស ៤:១៩

ដូច្នេះ ពួកអ្នកដែលរងទុក្ខ តាមព្រះហឫទ័យនៃព្រះ នោះត្រូវផ្ញើព្រលឹងខ្លួន ទុកនឹងព្រះដ៏បង្កបង្កើត ដែលទ្រង់ស្មោះត្រង់ ដោយខ្លួនប្រព្រឹត្តការល្អចុះ

១ពេត្រុស ៤:១៩

សៀវភៅកំណត់ហេតុរបស់ខ្ញុំ

សូមពណ៌នាអំពីបទពិសោធន៍នៃការឈឺចាប់ ឬពេលវេលានៃការរងទុក្ខលំបាកមួយរបស់លោកអ្នកផ្ទាល់។ តើបទពិសោធន៍នេះអាចនាំលោកអ្នកឲ្យចូលកាន់តែស៊ីជម្រៅក្នុងការដើរតាមព្រះជាម្ចាស់បានយ៉ាងដូចម្ដេច? តើបទពិសោធន៍នេះអាចជួយលោកអ្នកក្នុងការលើកទឹកចិត្តអ្នកដទៃបានយ៉ាងដូចម្ដេចដែរ?

ចំណុចគួរចងចាំ

សូមសរសេរបន្ថែមមួយឬពីរល្បះដាក់នៅចុងឃ្លាខាងក្រោមនេះដើម្បីសង្ខេប នូវចំណុចសំខាន់ៗដែលលោកអ្នកបានរៀនពីផ្នែកនីមួយៗនៅក្នុងជំពូកនេះ។

ការគ្រប់គ្រងដ៏ធំបំផុតរបស់ព្រះជាម្ចាស់

ព្រះជាម្ចាស់គ្រប់គ្រងកាលៈទេសៈដែលកើតឡើងចំពោះយើង។

គោលបំណងក្នុងការរងទុក្ខ

យើងគួរតែរំពឹងនូវការរងទុក្ខលំបាក ហើយទទួលបានលទ្ធផលជាភាពចាស់ទុំ។

ការឆ្លើយតបរបស់លោកអ្នកចំពោះការរងទុក្ខ

ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យយើងរៀនទុកចិត្ត ហើយនិងថ្វាយការអរព្រះគុណចំពោះទ្រង់គ្រប់ស្ថានភាពទាំងអស់ទោះបីវាមានការលំបាកក៏ដោយ។

ការលូតលាស់តាមរយៈការរងទុក្ខ

ការរងទុក្ខអាចស្អាងយើងសម្រាប់គោលបំណងរបស់ព្រះជាម្ចាស់។

ការចូលឲ្យបានស៊ីជម្រៅ

សូមជ្រើសរើសយកជម្រើសមួយក្នុងចំណោមជម្រើសទាំងពីរខាងក្រោមនេះ៖

ជម្រើស ក៖ សូមអានកណ្ឌគម្ពីរ រ៉ូម ៨:១៧-២៥។ តើលោកអ្នកព្រមរួមចំណែកក្នុងការរងទុក្ខជាមួយព្រះគ្រីស្ទក្នុងជីវិតនេះ ដើម្បីនឹងរួមចំណែកក្នុងការទទួលសិរីរុងរឿងជាមួយព្រះគ្រីស្ទនៅឯស្ថានសួគ៌ ដែរឬទេ? សូមពន្យល់៖

ជម្រើស ខ៖ ដោយសារតែការរងទុក្ខលំបាកជាការពិបាកយល់ នោះអាចធ្វើឲ្យយើងមានការភាន់ច្រលំនៅពេលដែលមនុស្សផ្សេងទៀតព្យាយាមពន្យល់ពីមូលហេតុនៃការរងទុក្ខលំបាកចំពោះយើង។

អ្នកខ្លះថាការរងទុក្ខមកពីអំពើបាប៖ "ការរងទុក្ខរបស់លោកអ្នកគឺកើតចេញមកពីបាបដែលលោកអ្នកប្រព្រឹត្ត។" ឯអ្នកផ្សេងទៀតផ្តោតទៅលើទំហំនៃសេចក្តីជំនឿដែលលោកអ្នកមាន៖ "ប្រសិនបើលោកអ្នកមានជំនឿខ្លាំងជាងនេះ ប្រហែលជាព្រះជាម្ចាស់នឹងប្រោសឲ្យលោកអ្នកជា"។ ហើយក៏មានអ្នកខ្លះទៀតយល់ឃើញថា បញ្ហាទាំងអស់នោះជាប់ទាក់ទងទៅនឹងការដែលយើង

មិនបានដើរតាមព្រះជាម្ចាស់ឲ្យបានត្រឹមត្រូវ៖ “ប្រសិនបើ ព្រះវិញ្ញាណបរិសុទ្ធដឹកនាំជីវិតលោកអ្នក នោះបញ្ហារបស់លោកអ្នកនឹងមិនមានទៀតទេ”។ ប៉ុន្តែ តើហេតុផលទាំងពីរនេះត្រឹមត្រូវតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរឬទេ? តើព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យយើងប្រើការឈឺចាប់យ៉ាងដូចម្តេច?

សូមពិនិត្យមើលគំនិតមួយចំនួនដែលផ្អែកលើព្រះគម្ពីរនៅផ្នែកខាងឆ្វេងនៃតារាងខាងក្រោមនេះដែលទាក់ទងជាមួយនឹងការលំបាកផ្សេងៗ។ ចំណុចទាំងនេះគឺគ្រាន់តែជាឧទាហរណ៍វិជ្ជមានមួយចំនួនដែលអាចកើតមាននៅពេលដែលយើងជួបទុក្ខលំបាកតែប៉ុណោះ។ បន្ទាប់មកសូមសរសេរត្រួសៗពីរបៀបដែលឧទាហរណ៍ទាំងនេះបានលើកទឹកចិត្តលោកអ្នក ឬការសរសើរដំកើងឬក៏ការអរព្រះគុណដែលលោកអ្នកចង់បញ្ជាក់ទៅកាន់ព្រះជាម្ចាស់ដាក់ក្នុងតារាងខាងស្តាំ។

បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ចំពោះយើង	ការឆ្លើយតបរបស់យើង
ទំនុកចិត្ត យើងខ្ញុំរាល់គ្នាជាដីឥដ្ឋ (អេសាយ ៦៤:៨) ហើយទ្រង់ជាជាងស្មូន យើងជាភាជនៈដី (២កូរិនថូស ៤:៧) ឥទ្ធិពលលើសលប់របស់ព្រះជាម្ចាស់នៅក្នុងយើង	

កម្លាំង យើងខ្ញុំខ្សោយ (២កូរិនថូស១២: ៩-១០) ទ្រង់ប្រទានកម្លាំង	
ការបន្សុទ្ធ និងចរិតចាស់ទុំ ការរងទុក្ខជួយអភិវឌ្ឍយើងឡើង (រ៉ូម ៥: ៣-៥)	
គ្មានភាពភ័យខ្លាច យើងប្រៀបដូចជាដើមឈើដែលចាក់ឫស ហើយបង្កើតផលផ្លែ (យេរេមា ១៧: ៨)	
ព័ន្ធកិច្ច យើងអាចកំសាន្តចិត្តអ្នកដទៃ (២កូរិនថូស ១: ៤) យើងធ្វើជាគំរូនៃសេចក្តីសង្ឃឹមដល់អ្នកដទៃ (១ពេត្រុស ៣: ១៤-១៥)	

សារៈសំខាន់នៃការសិក្សាព្រះគម្ពីរតាមលំដាប់សម្រាប់អ្នកដើរតាមព្រះគ្រីស្ទនៅក្នុងសតវត្សទី២១

គបស១

ជីវិតរបស់លោកអ្នកនៅក្នុងព្រះគ្រីស្ទ 978-0-9890481-0-1

លោកអ្នកនឹងរៀនចេះពីអត្ថន័យនៃការពេញដោយព្រះវិញ្ញាណបរិសុទ្ធ ដើម្បីឲ្យការស្តាប់បង្គាប់ ការសិក្សាព្រះគម្ពីរ ការអធិស្ឋាន ការប្រកបគ្នា និងការធ្វើបន្ទាល់ ក្លាយជាទម្លាប់ និងមានន័យពេញលេញនៅក្នុងជីវិតរស់នៅរបស់លោកអ្នក។



គបស២

អ្នកដើរតាមព្រះយេស៊ូវដែលពេញដោយព្រះវិញ្ញាណ 978-0-9890481-1-8

លោកអ្នកនឹងរៀនចេះនូវចំណុចសំខាន់ប្រាំយ៉ាងតាមរយៈសៀវភៅសិក្សាព្រះគម្ពីរដ៏ងាយស្រួលយល់នេះ ដើម្បីឲ្យបានក្លាយជាសិស្សរបស់ព្រះគ្រីស្ទដ៏រឹងមាំ និងពេញវ័យក្នុងការរស់នៅ។

គបស៣

ការដើរជាមួយព្រះគ្រីស្ទ 978-0-9890481-2-5

លោកអ្នកនឹងរៀនចេះនូវចំណុចសំខាន់ប្រាំយ៉ាងតាមរយៈសៀវភៅសិក្សាព្រះគម្ពីរដ៏ងាយស្រួលយល់នេះ ដើម្បីឲ្យបានក្លាយជាសិស្សរបស់ព្រះគ្រីស្ទដ៏រឹងមាំ និងពេញវ័យក្នុងការរស់នៅ។

គបស៥

មូលដ្ឋានគ្រឹះនៃជំនឿ 978-0-9890481-4-9

សៀវភៅនៃការសិក្សាព្រះគម្ពីរនេះនឹងជំរុញ ហើយនិងជួយលោកអ្នកក្នុងការយល់ពីព្រះជាម្ចាស់ ព្រះបន្ទូលរបស់ទ្រង់ ព្រះវិញ្ញាណបរិសុទ្ធ និងការតយុទ្ធខាងព្រលឹងវិញ្ញាណ និងយល់ពីការយាងត្រឡប់មកវិញរបស់ព្រះគ្រីស្ទ។

គបស៦

ការរីកចម្រើនក្នុងភាពជាសិស្ស 978-0-9890481-5-6

ការសិក្សាព្រះគម្ពីរពីសៀវភៅនេះនឹងផ្តល់ឲ្យលោកអ្នកនូវយល់ដ៏ជ្រៅជ្រះ និងការលើកទឹកចិត្តលោកអ្នកក្នុងការលូតលាស់ឲ្យក្លាយជាសិស្សដ៏ពិតរបស់ព្រះគ្រីស្ទតាមរយៈការចែកចាយព្រះពរដែលព្រះជាម្ចាស់បានប្រទានមកលោកអ្នក។

គបស៧

សេចក្តីសង្ឃឹមរបស់យើងនៅក្នុងព្រះគ្រីស្ទ 978-0-9890481-6-3

នៅក្នុងការសិក្សាកណ្ឌគម្ពីរ ១ថែស្សាឡូនីច លោកអ្នកនឹងរកឃើញរបៀបសិក្សាស្តីពីការវែកញែកដ៏ទូលំទូលាយមួយនៅក្នុងព្រះគម្ពីរ ហើយលោកអ្នកនឹងទទួលបានគោលការណ៍នៃការសិក្សាព្រះគម្ពីរដ៏មានឥទ្ធិពលដែលលោកអ្នកអាចប្រើប្រាស់ពេញមួយជីវិតនេះរហូត។

គបស **សៀវភៅសម្រាប់គ្រូ** 978-0-9890481-7-0

សៀវភៅនេះនឹងផ្តល់ឲ្យគ្រូបង្រៀននូវយល់ដ៏ជ្រៅជ្រះ និងព័ត៌មានដែលគ្រូបង្រៀនត្រូវដឹង ដើម្បីចែកចាយចំណុចសំខាន់នៃភាពជាសិស្សដ៏ពិតជាមួយអ្នកផ្សេងទៀត ដូចជាបង្រៀនមួយទល់មួយ ឬក៏បង្រៀនជាក្រុម។

NAVPRESS
Discipleship Inside Out®

ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ http://www.actioncambodia.org/dfd

For purchase information please visit http://www.actioncambodia.org/dfd